# បេឡាជាតិរបបសន្តិសុខសង្គម
## National Social Security Fund

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០១៦
# និងទិសដៅអនុវត្តបន្ត

ក្រុមការងារទប់ស្កាត់ករណីសន្លប់
និង បង្ការគ្រោះថ្នាក់ការងាររបស់
កម្មករនិយោជិត (ទ.ស.ប.ក)

- លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ
- លក្ខខណ្ឌការងារ
- អត្ថប្រយោជន៍របបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០១៦
# និងទិសដៅអនុវត្តបន្ត របស់ក្រុមការងារទប់ស្កាត់ករណីសន្លប់
# និងបញ្ហាគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត( ទ.ស.ប.ក )

រៀបចំដោយ: ក្រុមការងារទប់ស្កាត់ករណីសន្លប់ និង បញ្ហាគ្រោះថ្នាក់ការងារ
នៃបេឡាជាតិរបបសន្តិសុខសង្គម

បោះពុម្ពដោយ: បេឡាជាតិរបបសន្តិសុខសង្គម

ឆ្នាំ២០១៦

# មាតិកា


សេចក្តីសម្រេចបង្កើត និងបន្ថែមសមាសភាពក្រុមការងារ ទ.ស.ប.ក ....................................... I
ឧបករណ៍វាស់ស្ទង់របស់ក្រុមការងារ....................................................................................... VI
របាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០១៦ និង ទិសដៅអនុវត្តបន្ត........... ១
**ក.** លទ្ធផលការងារសម្រេចបាន................................................................................................ ១
១. ស្ថានភាពករណីកម្មករនិយោជិតសន្លប់....................................................................... ១
១.១ អំពីមូលហេតុបណ្តាលឱ្យកម្មករនិយោជិតសន្លប់.................................................. ១
១.២ អំពីវិធានការដាក់ឱ្យនិយោជកកែលំអ.................................................................. ៣
១.៣ ទិន្នន័យកម្មករនិយោជិតសន្លប់ក្នុងឆ្នាំ២០១៦......................................................... ៤
២. វិភាគទិន្នន័យកម្មករនិយោជិតសន្លប់ក្នុងឆ្នាំ២០១៦.................................................... ១០
២.១ មូលហេតុនៃកម្មករនិយោជិតសន្លប់...................................................................... ១០
២.២ រោងចក្រ និង កម្មករនិយោជិតសន្លប់ នៅតាមបណ្តារាជធានី-ខេត្ត........................... ១០
៣. ការវិវត្តនៃទិន្នន័យ.................................................................................................... ១១
៣.១ ទិន្នន័យរោងចក្រ និងកម្មករនិយោជិតសន្លប់ក្នុងឆ្នាំ២០១៥ និងក្នុងឆ្នាំ២០១៦........ ១១
៣.២ ការវិភាគប្រវត្តិទិន្នន័យជារួម ក្នុងឆ្នាំ២០១៥ និងក្នុងឆ្នាំ២០១៦.............................. ១២
៣.៣ ទិន្នន័យរោងចក្រ និង កម្មករសន្លប់តាមឆ្នាំចាស់ ក្នុងឆ្នាំ២០១៥ បានបន្តកើតក្នុងឆ្នាំ២០១៦ ទៀត........................................................................................ ១៤
៤. វដ្តនៃកម្មករនិយោជិតសន្លប់...................................................................................... ១៤
៥. ការសិក្សាស្រាវជ្រាវ និង ការការពារករណីកម្មករនិយោជិតសន្លប់................................ ១៥
៦. ការផ្សព្វផ្សាយអប់រំ.................................................................................................... ១៧
**ខ.** បញ្ហាប្រឈម.................................................................................................................. ៣៣
**គ.** ដំណោះស្រាយ................................................................................................................ ៣៣
**ឃ.** ការងារអនុវត្តបន្ត............................................................................................................ ៣៤
**ង.** សេចក្តីសន្និដ្ឋាន............................................................................................................. ៣៤
- ឯកសារយោង.......................................................................................................... ៣៦
- ទំនាក់ទំនង............................................................................................................. ៣៦

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០០២/១៥ ក.ប/ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ របស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១ ._**

ត្រូវបានបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមបណ្តាសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ វេជ្ជ. ប៉ុក វណ្ណថាត | ទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២. លោក ម៉េង ហុង | នាយករង នៃបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ៣. លោកវេជ្ជ. ហាន់ នព្វគុណ | ប្រធានការិយាល័យ នៃនាយកដ្ឋានពេទ្យការងារ | សមាជិក |
| ៤. លោក ផេង សុភាត | ប្រធានការិយាល័យ នៃនាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ៥. លោក ជាវ ប៊ុនរិទ្ធ | ប្រធានការិយាល័យ នៃប.ស.ស | សមាជិក |
| ៦. លោកវេជ្ជ. ទត ប៉ូឡារី | ប្រធានការិយាល័យ នៃប.ស.ស | សមាជិក |

**ប្រការ ២ ._**

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតតាមបណ្តាសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម មានភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងពិនិត្យរកមូលហេតុសន្លប់
- ចាត់វិធានការសង្គ្រោះបន្ទាន់ និងទប់ស្កាត់ការសន្លប់របស់កម្មករនិយោជិតនៅកន្លែងការងារ
- សម្របសម្រួល និងសហការជាមួយមន្ទីរពេទ្យ ពហុព្យាបាល ដើម្បីបង្កើតរូបមន្តព្យាបាលសន្លប់ និងកំណត់ពីតម្លៃព្យាបាល
- សម្របសម្រួល សហការជាមួយ ក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីដឹកជនរងគ្រោះទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ ពហុព្យាបាលប្រកបដោយសុវត្ថិភាព
- ផ្តល់យោបល់លើបញ្ហាហានិភ័យសំណង់ អគ្គិភ័យ អនាម័យ សុវត្ថិភាព សុខភាព និងលក្ខខណ្ឌការងារ
- ផ្តល់យោបល់ និងលើកសំណើចាត់វិធានការបង្ការហានិភ័យការងារជូននាយកបេឡាជាតិរបបសន្តិសុខសង្គម ។ នាយកប.ស.ស ត្រូវរាយការណ៍បន្តជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិនិត្យសម្រេច និងស្នើសុំអនុសាសន៍ណែនាំសម្រាប់អនុវត្តបន្ត
- រៀបចំណែនាំ និងប្រជុំផ្សព្វផ្សាយអប់រំកម្មវិធីបង្ការគ្រោះថ្នាក់ការងារ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់នាយកបេឡាជាតិរបបសន្តិសុខសង្គម

**ប្រការ ៣ ._**

សេចក្តីសម្រេចលេខ ០០៥/១១ កប/ស.ស.រ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមបណ្តាសហគ្រាស គ្រឹះស្ថាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤ ._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រុមប្រឹក្សាភិបាលនៃប.ស.ស នាយកបេឡាជាតិរបបសន្តិសុខសង្គម ប្រធាននាយកដ្ឋានពេទ្យការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
-គ្រប់ថ្នាក់ដឹកនាំក្រសួង
-គ្រប់សាលារាជធានី/ខេត្ត
-គ្រប់អង្គភាពក្រោមឱវាទក្រសួង
"ដើម្បីជូនជ្រាប"
-គ្រប់សហគ្រាស គ្រឹះស្ថាន "ដើម្បីសហការ"
-ដូចប្រការ ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ...........០២៥/១៦.......ក.ប/ស.ស.ក

## សេចក្តីសម្រេច
## ស្តីពី
## ការបន្ថែមសមាសភាពក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ របស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ-បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងអនុក្រឹត្យលេខ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញសេចក្តីសម្រេចលេខ០០២/១៥ ក.ប/ស.ស.រ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម
- លិខិតលេខ០៤៩/០៥/១៦ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ របស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- យោងតាមការចាំបាច់របស់បេឡាជាតិរបបសន្តិសុខសង្គម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# សម្រេច

**ប្រការ ១ .-**

ត្រូវបានបន្ថែមសមាសភាព **លោក ភាំង ម៉ូនីកា** អគ្គលេខាធិការរង ជាតំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ជាសមាជិកក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតតាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣ .-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកការងារ អគ្គាធិការ ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម ក្រុមប្រឹក្សាភិបាល នៃប.ស.ស នាយកបេឡាជាតិរបបសន្តិសុខសង្គម ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី/ខេត្ត
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ឧបករណ៍វាស់ស្ទង់របស់ក្រុមការងារ ន.ស.ប.ក



GasAlertMicro 5 (វាស់ $O_2$, CO, $H_2S$, $SO_2$, $CO_2$ ...)




Light Meter Extech (វាស់កម្រិតពន្លឺ)




Anemometer (វាស់សីតុណ្ហភាព សំណើម និងល្បឿនខ្យល់)




Sound Level Meter (វាស់កម្រិតសម្លេង)




Oxymeters (វាស់ចង្វាក់បេះដូង និង អ៊ុកស៊ីសែនក្នុងឈាម)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៦
# និងទិសដៅអនុវត្តបន្តរបស់ក្រុមការងារ ទ.ស.ប.ក

ការរក្សាបាននូវស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៥ នៃរដ្ឋសភាក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង ការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៥ បានទាក់ទាញវិនិយោគិនឱ្យមកវិនិយោគនៅកម្ពុជាយ៉ាងច្រើនលើគ្រប់វិស័យ ដោយបានបង្កើតការងារជូនដល់ប្រជាពលរដ្ឋទូទៅបានជាច្រើនក្នុងមួយឆ្នាំៗ ។ តាមរយៈកំណើននៃការវិនិយោគទាំងក្នុងស្រុក និងមកពីបរទេសបានធ្វើឱ្យវិស័យសេដ្ឋកិច្ចកម្ពុជាមានការរីកចំរើនគ្រប់ផ្នែក ក្នុងនោះក៏មានផ្នែកកាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើងផងដែរ ។ យោងលើការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយទប់ស្កាត់ និងកាត់បន្ថយកម្មករនិយោជិតសន្លប់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ជាសេនាធិការផ្ទាល់ ដែលមានតួនាទីជាអ្នកគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងមានក្រុមការងារទប់ស្កាត់ករណីកម្មករសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតតាមសហគ្រាស គ្រឹះស្ថាន។

ក្នុងឆ្នាំ២០១៦នេះ ក្រុមការងារ ទ.ស.ប.ក បានចុះអង្កេតស្វែងរកមូលហេតុ និងចាត់វិធានការកែលំអលើរោងចក្រដែលមានកម្មករនិយោជិតសន្លប់ដូចខាងក្រោម៖

## ក. លទ្ធផលការងារសម្រេចបាន

### ១ . ស្ថានភាពករណីកម្មករនិយោជិតសន្លប់

#### ១.១ អំពីមូលហេតុបណ្តាលឱ្យកម្មករនិយោជិតសន្លប់

ក្នុងឆ្នាំ២០១៦ នេះ ក្រុមការងារ ទ.ស.ប.ក បានចុះទៅតាមបណ្តារោងចក្រកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ដែលបានជួបឧប្បត្តិហេតុកម្មករនិយោជិតសន្លប់ ក្នុងនោះរកឃើញមូលហេតុ និងចំណុចប្រឈមជាច្រើនដូចខាងក្រោម៖

- អំពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ
  - **បញ្ហាគីមី**
    - ភាយក្លិនបង្គន់ចូលក្នុងអាគារផលិតកម្ម
    - ភាយក្លិនប្រេងបាតគ្រឿងចក្រចូលក្នុង**អា**គារផលិតកម្ម
    - សាយភាយក្លិនថ្នាំសម្លាប់សត្វល្អិត
    - សាយភាយក្លិនជីអាចម៍មាន់ចូលក្នុងប្រព័ន្ធបឺតខ្យល់
    - សាយភាយក្លិនក្រណាត់ដែលស្តុកទុកក្នុងអាគារផលិតកម្ម
    - ធុំក្លិនការបិតស្បែកជើង
    - ភាយក្លិនថ្នាំគីមីបាញ់ដាក់ស្រែចូលក្នុងអាគារផលិតកម្ម
  - **បញ្ហារូបសាស្ត្រ**
    - ការរៀបចំប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់មិនបានត្រឹមត្រូវតាមបច្ចេកទេស
    - ប្រព័ន្ធបឺតខ្យល់មានកំទិចកំទីក្រណាត់ និងធូលីដីច្រើន
    - ប្រព័ន្ធផ្លិតទឹកមានធូលីដី ស្លែ កំទិចកំទីក្រណាត់ច្រើន
    - ប្រព័ន្ធផ្លិតទឹកគ្មានសំណើម
    - ការបញ្ចេញបញ្ចូលខ្យល់មិនបានគ្រប់គ្រាន់
    - សាយភាយកំដៅ
    - ឮសម្លេងផ្លូងចរន្តអគ្គិសនី
    - របូតបំពង់ទុយោខ្យល់ពីប្រព័ន្ធបញ្ជូនខ្យល់ម៉ាស៊ីនសាប់ឡូហ្គោ
  - **បញ្ហាចិត្តសាស្ត្រសង្គម**
    - តានតឹងអារម្មណ៍
    - ស្លន់ស្លោ និងភិតភ័យតៗគ្នា
    - មានការនិយាយបំផ្លើសការពិតបណ្តាលឱ្យកម្មករិនីភិតភ័យ
  - **បញ្ហាវិទ្យាសាស្ត្ររៀបចំការងារ**
    - ការរៀបចំទុកដាក់សម្ភារៈគរខ្ពស់បាំងលំហូរខ្យល់
  - **បញ្ហាមេកានិច(N/A)**
  - **បញ្ហាជីវសាស្ត្រ**
    - របបចំណីអាហារមិនបានទៀងទាត់
  - **បញ្ហាការថែមម៉ោងធ្វើការ**
    - ថែមម៉ោងក្នុងមួយថ្ងៃ ២ម៉ោង ភាគច្រើនជាប្រចាំ

កត្តាថែមម៉ោងខាងលើមកពីកម្មករនិយោជិតបង្ខំចិត្តថែមម៉ោង ដោយសារចង់បានប្រាក់ឈ្នួលបន្ថែម ហើយម្តងម្កាលធ្វើឱ្យគាត់ទ្រោលការងារលែងបាន បូករួមនឹងការសម្រាកមិនបានគ្រប់គ្រាន់ ហូបអាហារមិនទៀងទាត់ និងគ្មានជីវជាតិក៏ជាហេតុបណ្តាលឱ្យកម្មករនិយោជិតសន្លប់ ។

### ១.២ អំពីវិធានការដាក់ឱ្យនិយោជកកែលំអ

ដើម្បីធានាការការពារសុខភាព និងសុវត្ថិភាពការងារ ពិសេសករណីកម្មករនិយោជិតសន្លប់ ក្រុមការងារ ទ.ស.ប.ក បានចុះទៅពិនិត្យអង្កេតស្វែងរកមូលហេតុ នឹងបានចាត់វិធានការជាបន្ទាន់ឱ្យម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ធ្វើការកែលំអ ដើម្បីទទួលបាននូវសុខដុមរមនា ក្នុងកន្លែងការងារដោយជំរុញឱ្យមានការកែលំអដូចតទៅ៖

- **អំពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ**
  - **ករណីបញ្ហាគីមី**
    - ផ្លាស់ប្តូរប្រព័ន្ធបឺតខ្យល់ដាក់ឱ្យនៅឆ្ងាយពីបង្គន់
    - បញ្ឈប់ការផ្លាស់ប្តូរប្រេងបាតគ្រឿងចក្រនៅក្បែរប្រព័ន្ធបឺតខ្យល់
    - ត្រូវសហការជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋ ដែលរស់នៅជុំវិញបរិវេណរោងចក្រឱ្យមានកិច្ចសហការផ្តល់ព័ត៌មានដល់គ្នាទៅវិញទៅមកទាក់ទងនឹងការប្រើប្រាស់ ជាតិគីមី និងជីធម្មជាតិ ដែលប្រជាជនប្រើប្រាស់ដាក់ស្រែ។
    - ត្រូវរៀបចំទុកដាក់ការបិតស្បែកជើងឱ្យបានត្រឹមត្រូវដើម្បីធានាថាមិនមានក្លិនសាយភាយក្នុងអាគារផលិតកម្ម។
    - រៀបចំទុកដាក់ក្រណាត់ដែលមានសាយភាយក្លិនឱ្យបានត្រឹមត្រូវ។
  - **ករណីបញ្ហារូបសាស្ត្រ**
    - រៀបចំប្រព័ន្ធបឺតខ្យល់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
    - ត្រូវលាងសម្អាតប្រព័ន្ធបឺតខ្យល់ឱ្យបានទៀងទាត់
    - បំពាក់ប្រព័ន្ធបឺតខ្យល់ឱ្យបានគ្រប់គ្រាន់
    - ពង្រឹងការត្រួតពិនិត្យប្រព័ន្ធភ្លើងឲ្យបានត្រឹមត្រូវ
    - ត្រួតពិនិត្យប្រព័ន្ធទុយោខ្យល់ម៉ាស៊ីនសាប់ឡូហ្គោ
  - **ករណីបញ្ហាចិត្តសាស្ត្រសង្គម**
    - ពន្យល់ណែនាំអប់រំកុំឱ្យមានភាពតានតឹងអារម្មណ៍
    - ផ្សព្វផ្សាយអប់រំពីគោលការណ៍ច្បាប់ និងបទប្បញ្ញត្តិនានា ។
  - **ករណីបញ្ហាវិទ្យាសាស្ត្ររៀបចំការងារ**
    - ណែនាំពីការរក្សាទុកដាក់សម្ភារកុំឱ្យបាំងលំហូរខ្យល់ចេញចូល
  - **ករណីបញ្ហាមេកានិច** (N/A)
  - **ករណីបញ្ហាជីវសាស្ត្រ**
    - ផ្សព្វផ្សាយដល់កម្មករនិយោជិតឱ្យបរិភោគអាហារឱ្យបានទៀតទាត់។
  - **ករណីការថែមម៉ោងធ្វើការ**
    - ការថែមម៉ោងត្រូវគោរពតាមច្បាប់ស្តីពីការងារ
    - ណែនាំកម្មករនិយោជិតពីអត្ថប្រយោជន៍នៃការសម្រាកឱ្យបានគ្រប់គ្រាន់ ដើម្បីធានាពីសុខភាពថាមពលក្នុងសកម្មភាពការងារថែមម៉ោង ។

## ១.៣ ទិន្នន័យកម្មករនិយោជិតសន្លប់ក្នុងឆ្នាំ២០១៦

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | រោងចក្រកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង | កម្មករ សរុប | កម្មករ គ្រោះថ្នាក់ | % | មូលហេតុ និង ការសន្និដ្ឋាន | អាការៈគ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ១ | ០៨/០២/២០១៦<br>០៩/០២/២០១៦ | LIN WEN CHIH SUNSTONE GARMENT ENTERPRISE Co., Ltd<br>-ផលិតសំលៀកបំពាក់<br>-ផ្លូវជាតិលេខ២ ភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល | ៤៨១ | ១២<br>១៩ | ៦.៤ | -ភាយក្លិនបង្គន់ចូលអាគារផលិតកម្ម<br>-ផ្អើលសន្លប់តៗគ្នា<br>-ថែមម៉ោងមួយខែមុនគ្រោះថ្នាក់ ២ម៉ោង ៩០% | -ចង្អោក្អួត<br>-វិលមុខ<br>-ត្រជាក់ចុងដៃចុងជើង<br>-ភិតភ័យ |
| ២ | ១២/០២/២០១៦ | EVERGREEN APPAREL (CAMBODIA) CO., LTD<br>-ផលិតសម្លៀកបំពាក់<br>-ផ្លូវលេខ១១០ ផ្ទះលេខ៩០ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ | ១,៨៥០ | ២០ | ១ | -ភាយក្លិនបង្គន់ចូលអាគារផលិតកម្ម<br>-ការរៀបចំប្រព័ន្ធខ្យល់មិនបានត្រឹមត្រូវ<br>-ផ្អើលសន្លប់តៗគ្នា<br>-ថែមម៉ោង ២ម៉ោងជារៀងរាល់ថ្ងៃ | -ពិបាកដកដង្ហើម<br>-ទន់ដៃទន់ជើង<br>-ណែនទ្រូង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | រោងចក្រកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង | កម្មករ សរុប | កម្មករ គ្រោះថ្នាក់ | % | មូលហេតុ និង ការសន្និដ្ឋាន | អាការៈគ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ៣ | ២៣/០២/២០១៦ | FIVE STARS COTTON GARMENT (CAMBODIA) LIMITED<br>- ផលិតសម្លៀកបំពាក់<br>- ផ្លូវជាតិលេខ០៣ ភូមិរះពោះ ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ | ៥៤៣ | ២១ | ៣.៨ | - ប្រព័ន្ធបឺតខ្យល់មានកំទេចកំទីក្រណាត់ និងធូលីដីច្រើន<br>- ផ្ញើលសន្លប់តៗគ្នា<br>- ការរៀបចំទុកដាក់សម្ភារៈគរខ្ពស់បាំងលំហូរខ្យល់<br>- ថែមម៉ោង ២ម៉ោងជារៀងរាល់ថ្ងៃ | -ភិតភ័យ<br>-ទន់ដៃទន់ជើង<br>-ចុកទ្រូង<br>-វិលមុខ<br>-រវើរវាយ |
| ៤ | ០១/០៣/២០១៦ | INDOCHIN APPAREL (CAMBODIA) LTD<br>- ផលិតសម្លៀកបំពាក់<br>- តំបន់សេដ្ឋកិច្ច7NG ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល | ១,៨០០ | ១៤ | ០.៧ | - ក្លាយក្លិនប្រេងបាតគ្រឿងចក្រចូលអាគារផលិតកម្ម<br>- តានតឹងអារម្មណ៍<br>- ប្រព័ន្ធផ្លិតទឹកមានធូលីដី ស្លែ កំទេចកំទីក្រណាត់ច្រើន<br>- ថែមម៉ោងជារៀងរាល់ថ្ងៃចំនួន៨០% | -ឈឺក្បាល<br>-វិលមុខ<br>-ចង់ចង្អោរ<br>-ត្រជាក់ចុងដៃចុងជើង<br>-ងងឹតមុខ<br>-ទន់ដៃទន់ជើង |
| ៥ | ០៤/០៣/២០១៦ | CHUN CHAO (CAMBODIA) CO., LTD<br>- ផលិតសម្លៀកបំពាក់ | ៣៨០ | ៤០ | ២០ | - ភាយក្លិនបង្គន់ចូលអាគារផលិតកម្ម<br>- ប្រព័ន្ធផ្លិតទឹកមានធូលីដី និងគ្មានសំណើម<br>- តានតឹងអារម្មណ៍ | -ថប់<br>-ណែនដើមទ្រូង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | រោងចក្រកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង | កម្មករ សរុប | កម្មករ គ្រោះថ្នាក់ | % | មូលហេតុ និង ការសន្និដ្ឋាន | អាការៈគ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| | ០៧/០៣/២០១៦ | - ផ្ទះលេខ២៦២B ផ្លូវលេខ១៣៦DT សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ | | ៣៩ | | - ថែមម៉ោង ២ម៉ោង ជារៀងរាល់ថ្ងៃ ៦០% | |
| ៦ | ៣០/០៥/២០១៦ | ORIENT INTERNATIONAL ENTERPRISE ( CAMBODIA ) GARMENT CO., LTD<br>- ផលិតសម្លៀកបំពាក់<br>- ផ្លូវជាតិលេខ៤ ឃុំវល្លិ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ១,១៥៧ | ១២០ | ១០.៣ | - សាយភាយក្លិនថ្នាំសម្លាប់សត្វល្អិត<br>- តានតឹងអារម្មណ៍<br>- ថែមម៉ោងចំនួន៩០% | - ឈឺក្បាល<br>- វិលមុខ<br>- ទន់ដៃទន់ជើង<br>- ពិបាកដកដង្ហើម |
| ៧ | ៣០/០៦/២០១៦ | LIDA ( CAMBODIA ) GARMENT CO., LTD<br>- ផលិតសម្លៀកបំពាក់<br>- ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | ៣១០ | ១៣ | ៤.១ | - ប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់ខុសលក្ខណៈបច្ចេកទេស<br>- ការរៀបចំស្តុកទំនិញមិនត្រឹមត្រូវ<br>- តានតឹងអារម្មណ៍<br>- ការថែមម៉ោង | - ទន់ដៃទន់ជើង<br>- រវើរវាយ<br>- ភិតភ័យ |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | រោងចក្រកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង | កម្មករ សរុប | កម្មករ គ្រោះថ្នាក់ | % | មូលហេតុ និង ការសន្និដ្ឋាន | អាការៈគ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ៨ | ០៧/០៧/២០១៦ | T Y FASHION ( CAMBODIA ) PLC<br>- ផលិតសម្លៀកបំពាក់<br>- ភូមិស្រែរាំង ឃុំទំនប់ ស្រុកពញាឮ ខេត្តកណ្តាល | ១,៣២០ | ៣០ | ២.២ | - សាយភាយក្លិនជីអាចម៍មាន់ចូលប្រព័ន្ធបឺតខ្យល់<br>- តានតឹងអារមេណ៍<br>- ការថែមម៉ោង | - ក្អួតចង្អោរ<br>- វិលមុខ<br>- ទន់ដៃទន់ជើង |
| ៩ | ១៨/០៧/២០១៦<br>២៩/០៧/២០១៦ | GRAND EAST FOOTWEAR INT'L CORP<br>- ផលិតស្បែកជើង<br>- ផ្លូវជាតិលេខ៤ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល | ១,២០៦ | ៨៩<br>៥០ | ១១.៥ | - សាយភាយក្លិនការបិតស្បែកជើងដែលទុកក្នុងអាគារផលិតកម្ម<br>- ការបញ្ចេញបញ្ចូលខ្យល់មិនគ្រប់គ្រាន់<br>- តានតឹងអារម្មណ៍<br>- របបចំណីអាហារមិនទៀងទាត់ | - ងងឹតមុខ<br>- ភិតភ័យ<br>- ទន់ដៃទន់ជើង |
| ១០ | ២១/០៧/២០១៦ | GARBOTEX TRADING COMPANY LIMITED<br>- ផលិតសម្លៀកបំពាក់<br>- ឃុំរកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ | ១,១០៩ | ៤៤ | ៣.៩ | ជម្ងឺតានតឹងអារម្មណ៍ ដោយញុះញង់ឱ្យមានកូដកម្ម | - ភិតភ័យ<br>- ញ័រទ្រូង<br>- ទន់ដៃទន់ជើង |
| ១១ | ០១/០៨/២០១៦<br>២៤/១១/២០១៦ | LI QIANG CORP<br>- ផលិតសម្លៀកបំពាក់<br>- ភូមិបាធាយ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម | ២០៦ | ៤៩<br>៣៧ | ៤១.៧ | - ភាយក្លិនថ្នាំគីមីបាញ់ដាក់ស្រែចូលក្នុងអាគារផលិតកម្ម<br>- ជម្ងឺតានតឹងអារម្មណ៍ | - ភិតភ័យ<br>- ក្អួតចង្អោរ<br>- វិលមុខ<br>- ទន់ដៃទន់ជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | រោងចក្រកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង | កម្មករ សរុប | កម្មករ គ្រោះថ្នាក់ | % | មូលហេតុ និង ការសន្និដ្ឋាន | អាការៈគ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ១២ | ០៣/០៨/១៦ | WINNING DRAGON LEATHERWARE ( CAMBODIA ) CO., LTD<br>- ផលិតកាបូប<br>- ផ្លូវលេខ៤១ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ២៦២៧ | ២៧ | ១ | - ការរៀបចំប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់មិនបានត្រឹមត្រូវតាមបច្ចេកទេស<br>- ជម្ងឺតានតឹងអារម្មណ៍ | - ស្រែកទ្រហោរយំ<br>- ទន់ដៃទន់ជើង<br>- ភិតភ័យ |
| ១៣ | ០៦/០៨/១៦ | SMART PEA GARMENT LTD<br>- ផលិតសម្លៀកបំពាក់<br>- សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ | ៨២៥ | ៦៦ | ៨ | - ធុំក្លិនក្រណាត់ដែលស្តុកទុកក្នុងអាគារ ផលិតកម្ម<br>- ជម្ងឺតានតឹងអារម្មណ៍<br>- ការថែមម៉ោង | - ឈឺក្បាល<br>- វិលមុខ<br>- ងងឹតមុខ<br>- ទន់ដៃទន់ជើង |
| ១៤ | ២៤/០៨/១៦ | TOP SUMMIT GARMENT INC<br>- ផលិតសម្លៀកបំពាក់<br>- សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ | ៤,៥២៧ | ៣៦ | ០.៧៩ | - ជម្ងឺតានតឹងអារម្មណ៍<br>- ការងារថែមម៉ោង | - ភិតភ័យ<br>- ទន់ដៃទន់ជើង |
| ១៥ | ៣១/០៨/១៦ | You Li 3 International ( CAMBODIA )<br>- ផលិតសម្លៀកបំពាក់<br>- សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង | ២៨០ | ២៦ | ៩.២ | - សាយភាយកំដៅ<br>- ភ័យតៗគ្នា | - ថប់ពិបាកដកដង្ហើម<br>- វិលមុខ<br>- ទន់ដៃទន់ជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | រោងចក្រកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង | កម្មករ សរុប | កម្មករ គ្រោះថ្នាក់ | % | មូលហេតុ និង ការសន្និដ្ឋាន | អាការៈគ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ១៦ | ១៣/០៩/១៦<br>១៥/១២/១៦ | HORIZON OUTDOOR (CAMBODIA) CO., LTD<br>- ផលិតសម្លៀកបំពាក់ និងកាបូប<br>- ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | ៤,៦៦៨ | ២១<br>១៩ | ០.៨ | - ឮសម្លេងឆ្លងចរន្តអគ្គិសនី<br>- របូតទុយោខ្យល់ពីប្រព័ន្ធបញ្ជូនម៉ាស៊ីនសាប់ឡូហ្គោ<br>- មានការនិយាយបំផ្លើសការពិតបណ្តាលឱ្យកម្មការិនី ភិតភ័យ<br>- ជម្ងឺតានតឹងអារម្មណ៍<br>- ការងារថែមម៉ោង | - ភិតភ័យ<br>- ទន់ដៃទន់ជើង |
| ១៧ | ០២/១១/១៦<br>០៤/១១/១៦ | WING STAR SHOES CO., LTD<br>- ផលិតស្បែកជើង<br>- ផ្លូវជាតិលេខ៣ ឃុំមហាឬស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ៧,៧៣៦ | ១៣៩<br>១៥១ | ៣.៧ | - ជម្ងឺតានតឹងអារម្មណ៍<br>- របបចំណីអាហារមិនគ្រប់គ្រាន់ | - រវើរវាយ<br>- ភិតភ័យ<br>- ទន់ដៃទន់ជើង |
| ១៨ | ០៧/១១/១៦ | YI GUANG INTERNATIONAL CO., LTD<br>- ផលិតស្បែកជើង<br>- ភូមិព្រៃពង្រ ឃុំកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ៥៩៦ | ៧៨ | ១៣.១ | - ការបញ្ចេញបញ្ចូលខ្យល់មិនបានត្រឹមត្រូវ<br>- តានតឹងអារម្មណ៍ ភ័យតៗគ្នា<br>- គេងមិនបានគ្រប់គ្រាន់ | - ងងឹតមុខ<br>- ទន់ដៃទន់ជើង |
| | | **សរុប ១៨ រោងចក្រ** | **៣១,៦២១** | **១,១៦០** | **៣.៦** | | |

## ២. វិភាគទិន្នន័យកម្មករនិយោជិតសន្លប់ក្នុងឆ្នាំ២០១៦

### ២.១ មូលហេតុនៃកម្មករនិយោជិតសន្លប់

✓ មូលហេតុនៃកម្មករនិយោជិតសន្លប់ទាំង ១៨ រោងចក្រកាត់ដេរ និងផលិតស្បែកជើង




✓ មូលហេតុនៃកម្មករនិយោជិតសន្លប់ទាំង ១៨ រោងចក្រ ធៀបនឹងរោងចក្រកាត់ដេរ និង ផលិតស្បែកជើង ដែលបានចុះបញ្ជីកានៅ ប.ស.ស ទាំង ១០០៦ រោងចក្រ




### ២.២ រោងចក្រ និងកម្មករនិយោជិតសន្លប់ នៅតាមបណ្តារាជធានី-ខេត្ត

- ចំនួនរោងចក្រដែលមានករណីកម្មករសន្លប់ទាំង ១៨ រោងចក្រ និង




- ចំនួនកម្មករនិយោជិតសន្លប់ ១,១៦០ នាក់



## ៣.ការវិភាគនៃទិន្នន័យ

### ៣.១ ទិន្នន័យរោងចក្រ និងកម្មករនិយោជិតសន្លប់ក្នុងឆ្នាំ២០១៥ និងក្នុងឆ្នាំ២០១៦

| ល.រ | រាជធានី/ខេត្ត | ឆ្នាំ២០១៦ | | ឆ្នាំ២០១៥ | | គិតជា % | |
|---|---|---|---|---|---|---|---|
| | | រោងចក្រ | កម្មករ | រោងចក្រ | កម្មករ | រោងចក្រ | កម្មករ |
| | សរុបរួម | ១៨ | ១,១៦០ | ៣២ | ១,៨០៦ | -៤៤ | -៣៦ |
| ១ | រាជធានីភ្នំពេញ | ៥ | ២១៤ | ៨ | ៣៥៩ | -៣៨ | -៤០ |
| ២ | ខេត្តកណ្តាល | ៤ | ២១៤ | ១៣ | ៨០០ | -៦៩ | -៧៣ |
| ៣ | ខេត្តកំពង់ឆ្នាំង | ១ | ៤០ | ២ | ៨៧ | -៥០ | -៥៤ |
| ៤ | ខេត្តស្វាយរៀង | ១ | ២៦ | ១ | ១០៤ | ០ | -៧៥ |
| ៥ | ខេត្តតាកែវ | ២ | ៦៥ | ២ | ១៤២ | ០ | -៥៤ |
| ៦ | ខេត្តកំពង់ស្ពឺ | ៤ | ៥១៥ | ៥ | ២៩៧ | -២០ | ៧៣ |
| ៧ | ខេត្តកំពង់ចាម | ១ | ៨៦ | - | - | ០ | ០ |
| ៨ | ខេត្តព្រៃវែង | - | - | ១ | ១៧ | -១០០ | -១០០ |






## ៣.២ ការវិភាគប្រវត្តិទិន្នន័យជារួមក្នុងឆ្នាំ២០១៥ និងក្នុងឆ្នាំ២០១៦

| ល.រ | បរិយាយ | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ | គិតជា% |
|---|---|---|---|---|
| ១ | រោងចក្រជួបបញ្ហាសន្លប់ | ១៨ | ៣២ | -៤៤ |
| ២ | កម្មករសន្លប់ | ១,១៦០ | ១,៨០៦ | -៣៦ |
| ៣ | កម្មករមិនបានសន្លប់ក្នុង រោងចក្រជួបបញ្ហាសន្លប់ | ៣១,៦២១ | ៤៥,២៥៩ | -៣០ |
| ៤ | រោងចក្រកាត់ដេរ/ស្បែកជើង បានចុះបញ្ជិកា ប.ស.ស | ១,០០៦ | ១,០៨៨ | -៨ |
| ៥ | កម្មករកាត់ដេរ/ស្បែកជើង បានចុះបញ្ជិកា ប.ស.ស | ៦៨៧,៦៨៦ | ៧១៤,៦៤០ | -៤ |
| ៦ | ផលធៀបរវាងល.រ ១ និង ៤ | ១.៧៨% | ២.៩៤% | -៣៩ |
| ៧ | ផលធៀបរវាងល.រ ២ និង ៥ | ០.១៦% | ០.២៥% | -៣៦ |
| ៨ | ផលធៀបរវាងល.រ ២ និង ៣ | ៣.៦៦% | ៣.៩៩% | -៨ |







៣/. ផលធៀបរវាង រោងចក្រជួបបញ្ហាសន្លប់
និង រោងចក្រកាត់ដេរ/ស្បែកជើង បានចុះបញ្ជិកា ប.ស.ស
៤.00%
៣.00%
២.00%
១.00%
0.00%
១.៧៨%
២.៩៤%
ឆ្នាំ២០១៦
ឆ្នាំ២០១៥


៤/. ផលធៀបរវាង កម្មករជួបបញ្ហាសន្លប់
និង កម្មករកាត់ដេរ/ស្បែកជើង បានចុះបញ្ជិកា ប.ស.ស
0.៣0%
0.២0%
0.១0%
0.00%
0.១៦%
0.២៥%
ឆ្នាំ២០១៦
ឆ្នាំ២០១៥


៥/. ផលធៀបរវាង កម្មករជួបបញ្ហាសន្លប់
និង កម្មករមិនបានសន្លប់ក្នុងរោងចក្រជួបបញ្ហាសន្លប់
៤.២0%
៤.00%
៣.៨0%
៣.៦0%
៣.៤0%
៣.៦៦%
៣.៩៩%
ឆ្នាំ២០១៦
ឆ្នាំ២០១៥

### ៣.៣ ទិន្នន័យរោងចក្រ និងកម្មករសន្លប់តាមឆ្នាំចាស់ ក្នុងឆ្នាំ២០១៥ បានបន្តកើតក្នុងឆ្នាំ២០១៦

| ល.រ | ឆ្នាំ | រោងចក្រជួបបញ្ហាសន្លប់ | | | កម្មករសន្លប់ | | |
|---|---|---|---|---|---|---|---|
| | | រោងចក្រ | រោងចក្រជួបបញ្ហាសន្លប់ បានបន្តកើត ឆ្នាំ២០១៦ | សរុប | កម្មករ | កម្មករសន្លប់ បានបន្តកើត ឆ្នាំ២០១៦ | សរុប |
| ១ | ឆ្នាំ២០១៦ | ១៨ | | | ១,១៦០ | | |
| ២ | ឆ្នាំ២០១៥ | ៣២ | ១ | ៣១ | ១,៨០៦ | ៦៣ | ១៧៤៣ |

ក្នុងឆ្នាំ២០១៦មានប្រវត្តិរោងចក្រធ្លាប់សន្លប់ក្នុងឆ្នាំ២០១៥ ចំនួន០១ រោងចក្រ (GRAND EAST FOOTWEAR INT'L CORP)។

## ៤. វដ្តនៃកម្មករនិយោជិតសន្លប់

★ ក្រាហ្វិចវដ្តនៃកម្មករនិយោជិតសន្លប់ មានពីរវដ្ត




❖ **វដ្តទី១**

- ពីខែមករាដល់ខែមេសាជារដូវដែលរោងចក្រទទួលបានការបញ្ជាទិញទំនិញថ្មី (បង្កើនសកម្មភាពផលិត)
  - បង្កើនការបន្ថែមម៉ោង ដើម្បីទុករយៈពេលសំរាករបស់កម្មករនិយោជិតពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឱ្យបានយូរ។
  - ជារដូវក្តៅ និងការសម្រាក(ជំណោក) មានរយៈពេលខ្លី។
- ខែឧសភា និង ខែមិថុនា មិនសូវមានបញ្ហាកម្មករនិយោជិតសន្លប់។

❖ **វដ្តទី២**

- ពីខែកក្កដាដល់ខែតុលាជារដូវដែលរោងចក្រទទួលបានការបញ្ជាទិញទំនិញបន្ថែម (បង្កើនសកម្មភាពផលិត)
  - បង្កើនការបន្ថែមម៉ោង ដើម្បីទុករយៈពេលសំរាករបស់កម្មករនិយោជិតនាពេលបុណ្យភ្ជុំបិណ្ឌឱ្យបានយូរ

- ជារដូវវស្សា ដកស្ទូង ច្រូតកាត់ និងការសម្រាក(ដំណេក) មានរយៈពេលខ្លី។
- ខែវិច្ឆិកា និង ខែធ្នូ មិនសូវមានបញ្ហាកម្មករនិយោជិតសន្លប់។

## ៥. ការសិក្សាស្រាវជ្រាវ និង ការការពារករណីកម្មករនិយោជិតសន្លប់

Mass Psychogenic illness គឺជាជំងឺមួយប្រភេទដែលគេសំដៅលើជំងឺ Mass hysteria ជំងឺនេះត្រូវបានគេរកឃើញប្រហែល៦០០ឆ្នាំមុនមកហើយ ។ វាជាជំងឺដែលមានលក្ខណៈកម្រជួបប្រទះក្នុងអំឡុងពេលសិក្សា ជំងឺនេះកើតឡើងនៅក្នុងរោងចក្រឧស្សាហកម្មមួយចំនួនក្នុងប្រទេសអង់គ្លេស បារាំង អាល្លឺម៉ង់ អ៊ីតាលី រុស្ស៊ី សហរដ្ឋអាមេរិច និងសាំងហ្គាពួរ ...។

Mass Psychogenic illness "MPI" = ជំងឺហ្វូងមនុស្សមានអារម្មណ៍ខ្លាំងក្លា

- M = Mass (ក្រុមមនុស្ស ឬ ហ្វូងមនុស្ស)
- P = Psychogenic (អារម្មណ៍ខ្លាំងក្លា)
- I = illness (ជំងឺ)
- Mass Hysteria (ជំងឺស្នេហ៍ហ្វូង)

នៅពេលដែលមនុស្សនៅក្នុងក្រុមចាប់ផ្តើមគិតថា ពួកគេបានឆ្លងជំងឺ ដែលមានគ្រោះថ្នាក់ដូចជា៖ មេរោគមួយ ឬ ក៏ជាតិពុលដែលបង្កើតដោយអតិសុខុមប្រាណ ។ ពួកគេអាចមានរោគសញ្ញាឈឺក្បាល វិលមុខ ក្អួតចង្អោរ ថប់ដង្ហើម សុខភាពខ្សោយ មានអារម្មណ៍ទន់ដៃទន់ជើងលែងដឹងខ្លួន។ប្រសិនបើមានមនុស្សច្រើននៅក្នុងក្រុមចាប់ផ្តើមមានអារម្មណ៍ថាឈឺនៅពេលតែមួយ យើងអាចសន្និដ្ឋានថាពួកគេអាចមានជំងឺ Mass Psychogenic illness ។ ហើយជំងឺប្រភេទនេះ ច្រើនកើតឡើងលើក្រុមសិស្សសាលា និង ក្រុមកម្មករ។ នៅពេលខ្លះជំងឺ Mass Psychogenic illness ក៏ត្រូវបានគេហៅថាជំងឺ Mass hysteria ឬ Epidemic hysteria (ជំងឺស្នេហ៍ហ្វូង)។

ក. ក្នុងឆ្នាំ ១៩៩៩ សិស្សអនុវិទ្យាល័យនៃប្រទេសប៊ែលហ្សិក បានផ្ទុះឡើងនូវជំងឺ MPI ដែលបង្កឱ្យមានជនរងគ្រោះចំនួន ១២២ នាក់ ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ។ ភាគច្រើននៃជនរងគ្រោះគឺជាមនុស្សស្រី ។

- ការសន្និដ្ឋានលើកដំបូងគឺ បណ្តាលមកពីពុលភេសជ្ជៈ Coca Cola
- តែក្រោយការពិនិត្យដោយមន្ទីរពិសោធន៍ឯករាជ្យលើផលិតផល CocaCola រួចហើយបានបញ្ជាក់ថាគ្មានសារធាតុគីមី ដែលបង្កឱ្យមានរោគសញ្ញាទាក់ទងនឹងជំងឺ MPI នោះ ទេ
- អ្នកជំនាញផ្នែកសុខាភិបាលបានបញ្ចប់សេចក្តីសន្និដ្ឋានថា វាជាការរីករាលដាលឆ្លងមកពីជំងឺ MPI ។

ខ. មន្ទីរពិសោធន៍នៃប្រទេសសាំងហ្គាពួរបានធ្វើការសិក្សាលើការរីករាលដាលនៃជំងឺ MPI ក្នុងរោងចក្រជាច្រើនក្នុងប្រទេសនៅចន្លោះឆ្នាំ១៩៧៣ រហូតដល់ ១៩៧៨។ ក្រោយការសិក្សាបានបង្ហាញលទ្ធផលថា ៖

- កម្មករនិយោជិតមានអាការៈភ័យខ្លាច និង ភ្លេចភ្លាំងស្មារតី
- កម្មករនិយោជិតមានអារម្មណ៍ថាត្រជាក់ (ខ្លួនប្រាណ)
- កម្មករនិយោជិតមានអារម្មណ៍ស្ពឹកស្រពន់
- កម្មករនិយោជិតចាប់ផ្តើមសន្លប់

- ជំងឺនេះភាគច្រើនកើតឡើងលើស្ត្រី

គ. ក្នុងឆ្នាំ១៩៧៩ រោងចក្រស្បែកជើងមួយនៃសហរដ្ឋអាមេរិកបានផ្ទុះឡើងនូវជំងឺ MPI នាយកដ្ឋានសុខភាពនៃប្រទេសសហរដ្ឋអាមេរិក បានរៀបចំគម្រោងស៊ើបអង្កេតលើឧស្សាហកម្ម ៖

- ដោយការសាកសួរលើកម្មករនិយោជិតចំនួន ៥០-៧៥ នាក់ (ដែលបានឆ្លងនូវជំងឺនេះ)

- លទ្ធផលបានបង្ហាញថាកម្មករនិយោជិតមានរោគសញ្ញាដូចជា ៖ ឈឺក្បាល វិលមុខ ក្អួតចង្អោរ ថប់ ដង្ហើម និងមានអារម្មណ៍ទន់ដៃទន់ជើង ដោយមូលហេតុធំក្លិនចម្លែកនូវនឹងកន្លែងធ្វើការ

- មូលហេតុបណ្តាលឱ្យកើតឡើងនូវជំងឺនេះបណ្តាលមកពី ៖ បរិស្ថានជុំវិញខ្លួនមានភាពស្មុគស្មាញក្នុងការងារ (Job stress) និងភាពស្មុគស្មាញនៅក្នុងជីវិត (Life stress) ។

**ការរីករាលដាលឆ្លងនេះនឹងមានការស្រាកស្រាន្តទៅវិញក្នុងរយៈពេលប្រហែល១សប្តាហ៍ ។**

✓ **មូលហេតុបង្កឱ្យមានការផ្ទុះឡើងនូវជំងឺ MPI**

នៅពេលដែលមានបុគ្គលណាមួយមានអាការៈឈឺក្បាល វិលមុខ ក្អួតចង្អោរ ថប់ដង្ហើម និងមានអារម្មណ៍ទន់ដៃទន់ជើង ហើយអ្នករួមការងារដែលនៅក្បែរជនរងគ្រោះ គិតថាខ្លួនបានឆ្លងនូវជំងឺនេះក៏មានអាការៈដូចគ្នានឹងជនរងគ្រោះដែរ ជាអាទិ៍ ៖

- សន្លប់តគ្នា
- ភាពស្មុគស្មាញចិត្ត (Job stress and Life stress)
- ការសាយភាយក្លិនមិនល្អ
- ការសាយភាយនូវជាតិពុល
- បរិស្ថានមិនល្អ
- អគ្គិភ័យ (ផ្សែង)
- ពុលសារជាតិគីមី
- ខ្វះអុកស៊ីសែន ។ល។

✓ **រោគសញ្ញា**

- ឈឺក្បាល វិលមុខ ចង្អោរ(ការគើ) ចុកពោះ ក្អក អស់កម្លាំងហេវហត់ ងងុយគេង
- ឈឺ/ក្តៅបំពង់ក ដកដង្ហើមដង្ហក់ៗ ឬ ពិបាកដកដង្ហើម ក្តៅក្នុងភ្នែក តឹងណែនដើមទ្រូង

✓ **ដំណោះស្រាយ**

- ជម្លៀសមនុស្សចេញពីទីកន្លែងដែលមានការផ្ទុះឡើងនូវជំងឺ
- ថែទាំអ្នកជំងឺម្នាក់ៗ ដោយមានការពិនិត្យពិច្ច័យពីគ្រូពេទ្យ និង ប្រាប់ទៅពួកគាត់ថា "ពួកគាត់អត់មានជំងឺអ្វីធ្ងន់ធ្ងរទេ"
- ថែរក្សា ឬ ជម្លៀសមនុស្សដែលមានអារម្មណ៍ថាឈឺ ឱ្យនៅឆ្ងាយពីតំបន់ជ្រួលច្របល់ និងមានសំពាធ
- បំបែកក្រុមមនុស្សមានជំងឺ និង គ្មានជំងឺឱ្យនៅដាច់ដោយឡែកពីគ្នា
- បំបែកក្រុមមនុស្សពីមានចំនួនច្រើនឱ្យនៅចំនួនតិច (ជៀសវាងការប្រមូលផ្តុំគ្នា)

- ធ្វើការត្រួតពិនិត្យតាមលក្ខណៈបច្ចេកទេស នៅទីកន្លែងដែលមានផ្ទុះឡើងនូវជំងឺ
- ព្យាយាមធ្វើឱ្យក្រុមកម្មករនិយោជិតជឿថា ទីកន្លែងនោះមានសុវត្ថិភាព និងត្រលប់ទៅធ្វើការជាធម្មតា (ក្រោយការត្រួតពិនិត្យចប់)
- ធ្វើរោគវិនិច្ឆ័យលើប្រភេទជំងឺ និង រោគសញ្ញាផ្សេងៗ
- ត្រួតពិនិត្យមើលកំរិតអុកស៊ីសែន និង បរិស្ថានជុំវិញ
- ត្រួតពិនិត្យរកសារធាតុគីមី ដែលអាចមានផលប៉ះពាល់ដល់សុខភាព
- ព្យាយាមរកមនុស្ស ដែលកើតជំងឺនេះមុនគេ នៅកន្លែងដែលមានផ្ទុះឡើងនូវជំងឺនេះ
- ធ្វើការកាត់បន្ថយលើការព្យាបាលមួយចំនួនដែលមិនមានសារៈសំខាន់

យោងតាមគេហទំព័រ ៖ **http://en.m.wikipedia.org/wiki/mass_psychogenic_illness**

## ៦. ការផ្សព្វផ្សាយអប់រំ

ការផ្សព្វផ្សាយអប់រំនេះ បាននិងកំពុងរៀបចំឡើងតាំងពីឆមាសទី២ ឆ្នាំ២០១២ មក ដែលមាន ប.ស.ស នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកគ្រប់គ្រងការចំណាយ ក្នុងទិសដៅបង្ការគ្រោះថ្នាក់ការងារ ដោយលើកកម្ពស់លក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ ពិសេសករណីកម្មករនិយោជិតសន្លប់ ។ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយអប់រំនេះ ក្រុមការងារ ទ.ស.ប.ក ក៏មានឯកសារពាក់ព័ន្ធមួយចំនួនដូចជា៖

- ការធ្វើបទបង្ហាញស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់និងវិធានការបង្ការគ្រោះថ្នាក់ការងារ៖
  - លក្ខខណ្ឌការងារ
  - លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ
  - អត្ថប្រយោជន៍របបសន្តិសុខសង្គម។

### សម្រាប់ផ្នែកលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ

✓ **ស្ត្រី ឬ បុរសដែលត្រូវការថាមពលច្រើនរួមមាន អ្នកចំការ អ្នកស្រែ អត្តពលករ ចំនួន ២៤០០ កាឡូរី/១ថ្ងៃ**

| ល.រ | មុខអាហារ | កាឡូរី | បរិយាយ |
|---|---|---|---|
| ១ | បាយ | ៧២០ | ៦០ ក្រ (១២ ស្លាបព្រាបាយ) |
| ២ | បន្លែ | ២៤០ | ៤០ ក្រ (៦ ស្លាបព្រាបាយ) |
| ៣ | ផ្លែឈើ | ... | ៥ ផ្លែ (៥ ចំណិត) |
| ៤ | សាច់មាន់ គោ ជ្រូក ត្រី ស៊ុត មឹក កំពិស | ១៨០ | ១២ ក្រ (១២ ស្លាបព្រាសម្ល) |
| ៥ | ទឹកដោះគោ | ... | ១ កែវ (២០០ ml) |
| ៦ | ត្រីឆ្អឹងតូចៗ (ត្រីលិញ ឬ ត្រីរៀល) | ៣០ | ១៥ ក្រ (២ ស្លាបព្រាសម្ល) |

កំណត់សំគាល់ ៖

- ១ស្លាបព្រាបាយ មានប្រហែល ៦០ក្រ
- ១ស្លាបព្រាបាយដំណើបស្មើនឹង២ស្លាបព្រាបាយធម្មតា
- ១ស្លាបព្រានំបញ្ចុកស្មើនឹង ៦០ក្រ
- ១បន្ទះនំប៉័ងស្មើនឹង ៣០ក្រ
- ១ស្លាបព្រាបាយនៃបន្លែស្មើនឹង ៤០ក្រ
- ១ស្លាបព្រាសម្លស្មើនឹង ១៥ក្រសាច់
- ១ចំណិតផ្លែឈើនៅទីនេះគេចាត់ទុកស្មើនឹងចេក១ផ្លែ ក្រូច១ផ្លែ សាវម៉ាវ៤ ត្រប់បែកមួយចំហៀង ផ្លែល្ហុង និង ម្នាស់ គេគិតថាពុះ១ផ្លែជា៦ចំណិត ។

✓ **ការសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ (ករណីគ្រោះថ្នាក់ស្រាល)**

១. ការពិនិត្យមើលដង្ហើមចេញ ចូល

- ត្រូវពិនិត្យមើលជាប្រញាប់ថាខ្យល់មានចេញចូលតាមច្រមុះ តាមមាត់របស់ជនរងគ្រោះដែរ ឬទេ?
- ប្រសិនបើជនរងគ្រោះសន្លប់បាត់ស្មារតី ហើយដេកផ្ងារនោះ អាចថប់ដង្ហើមបានដោយសារអណ្តាតរបស់គេរមូរចូលទៅក្នុងបំពង់ក ហើយធ្វើឱ្យស្ទះខ្យល់ដកដង្ហើម
- អាស្រ័យបែបនេះ បើជនរងគ្រោះសន្លប់ ត្រូវដាក់ឱ្យដេកផ្អៀង មុខចុះក្រោម ត្រូវមានការប្រុងប្រយ័ត្ន ប្រសិនបើគេអាចមានរបួសនៅក។

២. ការដកដង្ហើមសិប្បនិម្មិត (គ្មានដង្ហើម)

- ប្រសិនបើជនរងគ្រោះគ្រាន់តែដួល ត្រូវទ្រកដោយដៃម្ខាង ហើយដៃម្ខាងទៀតដាក់លើថ្ងាស
- ចាប់ភ្ញោកក្បាល ជនរងគ្រោះទៅក្រោយឱ្យខ្លាំងតាមដែលអាចធ្វើទៅបាន
- យកមាត់ច្បាមរន្ធច្រមុះ ឬ ខ្ទប់រន្ធច្រមុះ (យកមាត់ និង មាត់ជនរងគ្រោះ ច្បាមរន្ធច្រមុះ ឬ ខ្ទប់រន្ធច្រមុះដោយបឺតផ្លុំខ្យល់តាមនេះ)
- ត្រូវសម្លឹងមើលទ្រូងរបស់ជនរងគ្រោះ ហើយកាលណាឃើញកំរើកនោះមានន័យថា សួតចាប់ផ្តើមទទួលយកខ្យល់ហើយ
- បន្តធ្វើចលនាបឺតផ្លុំបែបនេះក្នុងចន្លោះរយៈពេលប្រាំវិនាទីម្តង
- បន្តធ្វើការដកដង្ហើមសិប្បនិម្មិតរហូតទាល់តែជនរងគ្រោះចាប់ផ្តើមដកដង្ហើម ឬ បុគ្គលិកពេទ្យមកដល់ ។



៣. ការឃាត់ឈាម



- ប្រសិនបើជនរងគ្រោះមានហូរឈាម ត្រូវព្យាយាមឃាត់ឈាមដោយប្របាច់ខ្ទប់មុខរបួស និង ដាក់ដៃជើងអ្នករបួសសណ្ដូបត្រង់។

៤. ការបង្ការការគាំងបេះដូង

- ការភ័យតក់ស្លុតចំពោះគ្រោះថ្នាក់ធ្ងន់ធ្ងរអាចបណ្តាលឱ្យស្លាប់បាន ប៉ុន្តែប្រការនេះយើងអាចបង្ការបាន៖
  - ដំបូងត្រូវពិនិត្យមើលថាជនរងគ្រោះនៅមានដង្ហើម ឬ អត់
  - បន្ទាប់មកត្រូវបង្ការការភ័យតក់ស្លុតដោយផ្តេកជនរងគ្រោះទៅចំហៀង
  - ស្រាយបន្ធូរសម្លៀកបំពាក់ដែលចងរឹតតឹង
  - ដណ្តប់ភួយឱ្យជនរងគ្រោះ
  - កុំឱ្យអ្វីទៅជនរងគ្រោះផឹកឱ្យសោះលើកលែងតែមានបញ្ជាពីគ្រូពេទ្យ
  - ការពារជនរងគ្រោះពីពន្លឺព្រះអាទិត្យផ្ទាល់
  - យកទឹកផ្សើមបបូរមាត់ និង អណ្តាតជនរងគ្រោះបើចាំបាច់



៥. របួស មុត រលាត់



- របួសភាគច្រើនច្រើនតែកើតចេញពីគ្រោះថ្នាក់ដោយសារមុត រលាត់
- ប្រសិនបើមុត និង រលាត់មានភាពស្រាលៗ សើៗ ដំបូងត្រូវឃាត់ឈាម បន្ទាប់មកត្រូវលាងសំអាតមុតរបួសដោយប្រុងប្រយ័ត្ន។ ក្រោយពេលសំអាតរួចហើយត្រូវរុំមុខរបួសដោយក្រណាត់ស្បៃស្អាត

- ជានិច្ចកាលរបួសធ្ងន់ និង មុតជ្រៅត្រូវព្យាបាលដោយវេជ្ជបណ្ឌិត ក្នុងករណីបែបនេះ ការសង្គ្រោះបន្ទាន់គឺគ្រាន់តែជួយដាក់ និង រុំមុខរបួសតែប៉ុណ្ណោះ ។

៦. ការរលាក

- ប្រសិនបើសម្លៀកបំពាក់មនុស្សម្នាក់ត្រូវភ្លើងឆេះវិធីដ៏ល្អប្រសើរដើម្បីពន្លត់ភ្លើងគឺឱ្យជនរងគ្រោះប្រមៀលខ្លួននៅលើកំរាលឥដ្ឋ ឬ នៅក្នុងភួយ
- ក្រោយពន្លត់ភ្លើងរួចហើយ ត្រូវយកទឹកត្រជាក់ទៅចាក់លើកន្លែងរលាក ត្រូវគ្របមុខរលាកហើយនាំយកជនរងគ្រោះទៅមន្ទីរពេទ្យជាបន្ទាន់
- ដាច់ខាតមិនត្រូវប្រើម្សៅ ខ្លាញ់ប័រ ក្រែម អាល់កុល អ៊ីយ៉ូត ឬ ជាតិដូចខាងលើនេះទៅលើមុខរលាកឱ្យសោះ ។ ដាច់ខាតកុំបំបែកពងទឹកនៅលើមុខរលាកឱ្យសោះ ។



៧. របួសដោយសារវត្ថុធាតុកាត់ស្បែក



- ប្រសិនបើនរណាម្នាក់ធ្វើឱ្យកំពប់ទឹកអាស៊ីដ ឬ ជាតិអាកាឡាំងទៅលើស្បែករបស់បងប្អូន នោះបងប្អូនត្រូវលាងទឹកភ្លាម។ បន្ទាប់មកមុខរបួសដែលបណ្តាលមកពីការកាត់ស្បែកដោយសារវត្ថុរាវ កាត់ស៊ីស្បែកណាមួយច្រើនតែមានសភាពអាក្រក់ជាងអ្វីដែលយើងមើលមិនឃើញ
- អាស្រ័យហេតុនេះទោះបីមិនឃើញថាមានសភាពធ្ងន់ធ្ងរយ៉ាងណាក៏ដោយត្រូវតែទៅរកវេជ្ជបណ្ឌិតព្យាបាលដាច់ខាត
- ជាតិគីមីដូចជា៖ អាស៊ីដ ឬ ទឹកក្បុងអាចឱ្យរលាកយ៉ាងឆាប់រហ័ស និង ធ្ងន់ធ្ងរទៀតផង
- បើវត្ថុធាតុរាវនោះខ្ទាតទៅលើភ្នែក ឬ ទៅលើខ្លួនប្រាណរបស់អ្នក នោះអ្នកត្រូវលាងទឹកចោលភ្លាម។ ទឹកផ្កាឈូក និង ទឹកបាញ់លាងភ្នែកត្រូវស្ថិតនៅជិតកន្លែងធ្វើការបំផុត។



៨. របួសភ្នែក

- ធូលីនៅក្នុងភ្នែក គឺជាការឈឺចាប់ជាទូទៅ ប្រសិនបើសម្រាមចូលភ្នែកអ្នកហើយ វាស្ថិតនៅសើៗខាងលើ នោះអ្នកអាចយកវាចេញភ្លាមដោយលាងដៃនឹងទឹក ឬ

ផ្ចិតដោយប្រើសំឡីសើមៗ ឬ ប្រើចុងជ្រុង
កន្សែងដៃស្អាតក៏បាន
ជាតិអាកាឡាំង អាស៊ីដ នៅក្នុងភ្នែកអាចបណ្តាលឱ្យឈឺចាប់យ៉ាងខ្លាំង
អ្នកត្រូវលាងភ្នែកនឹងទឹកភ្លាម យ៉ាងហោចណាស់ក៏រយៈពេល ១០ នាទីដែរ
ក្រោយលាងរួចហើយ អ្នកត្រូវទៅឱ្យគ្រូពេទ្យពិនិត្យមើលជាបន្ទាន់។

៩. របួសដោយសារអគ្គិសនី



- ការឆក់ដោយអគ្គិសនី ប៉ះពាល់ទៅលើបេះដូង ហើយអាចបណ្តាលឱ្យស្លាប់ភ្លាមៗ។ អ្នកត្រូវអគ្គិសនីឆក់ត្រូវរងគ្រោះបន្ថែម ដោយសារការភ្លាក់ធ្លាក់ពីលើរន្ទាជណ្តើរ ឬពីលើទីកន្លែងខ្ពស់
- ប្រសិនបើជនរងគ្រោះនៅតែប៉ះជាប់ នឹងគ្រឿងប្រដាប់អគ្គិសនី ត្រូវកាត់ចរន្ត ដោយបិទកុងតាក់ ឬ ប្រភពអគ្គិសនីភ្លាម។ ប្រសិនបើមិនអាចបិទបានទេនោះ ត្រូវប្រើ ប្រាស់វត្ថុណាដែលវែងស្ងួត ស្អាត និងមិន ចំលងភ្លើងដើម្បីទាញជនរងគ្រោះចេញឱ្យឆ្ងាយពីកន្លែងឆក់
- នៅពេលជនរងគ្រោះត្រូវបានទាញចេញឆ្ងាយពីកន្លែងឆក់រួចហើយត្រូវធ្វើចលនា
- ស្ទួត បេះដូងប្រសិនបើចាំបាច់ ។ កុំខាតពេលវេលា និង យកជនរងគ្រោះទៅកន្លែង ដទៃទៀត។តាមក្បួនច្បាប់គេមិនត្រូវព្យាបាលស្នាមរលាកដោយសារអគ្គិសនីឡើយ។

១០. ការបាក់អវៈយវៈ ការគ្រេច ការភ្លាត់ឆ្អឹង



- ក្នុងករណីមានសង្ស័យថាមានបាក់ឆ្អឹងអវៈយវៈត្រង់កន្លែងណាមួយ ជនរងគ្រោះ ត្រូវដាក់ឱ្យនៅនឹងមួយកន្លែង កុំបីកំរើកឱ្យសោះ ដើម្បីការពារការបាក់កាន់តែ ធ្ងន់ធ្ងរឡើងថែមទៀត និង ដើម្បីបន្ថយការឈឺចាប់ផង ។ ត្រូវរណបអបឆ្អឹង ដែលបាក់ដោយដំបងឈើពីរ ឬ ក៏យកក្រដាសកាសែតមករុំព័ទ្ធដាក់ទម្ររណប នៅខាងក្រៅសម្លៀកបំពាក់ ហើយយកក្រណាត់រុំបន្ថែមមួយជាន់ពីលើទៀត។ រណប ឬ ទម្រអាចឱ្យវែងបន្តិច ដើម្បីអាចទប់ពីលើពីក្រោមកន្លែងដែលឆ្អឹងត្រូវ បាក់គ្រេចភ្លាត់នោះ។ដើម្បីជៀសវាងការសង្កត់ដោយមិនបាច់ទៅលើកន្លែងបាក់ នោះ គេអាចដាក់សំឡីនៅចន្លោះគ្រឿងរណប និង អវៈយវៈ ។

- នៅក្នុងករណីបាក់ដៃ ឬ ជើង ចូរកុំឱ្យរបួសកាន់តែធ្ងន់ធ្ងរទៀត ដោយការរឹតបន្តឹងអវៈយវៈដែលបាក់នោះ ។ រូបគំនូរខាងក្រោមនេះ បង្ហាញពីរបៀបលើកដាក់ក៏សមស្របមនុស្សដែលបាក់ជើង។
- ជើងបាក់ត្រូវទ្រដោយរុំក្តួយទាំងសងខាងដើម្បីបន្ថយចលនានៅកន្លែងបាក់ ។ គ្រប់កន្លែងធ្វើការ និង ក្រុមហ៊ុនទាំងអស់ត្រូវតែមានគំរោងផែនការ និង ការរៀបចំដឹកជញ្ជូនឱ្យបានឆាប់រហ័សទៅកាន់មន្ទីរពេទ្យ និង ព្យាបាលរាល់របួសទាំងអស់ដែលអាចកើតឡើងជាយថាហេតុ ។

១១. របួសលលាដ៏ក្បាល និង ឆ្អឹងខ្នង

 

- ការប៉ះទង្គិចខ្លាំងទៅលើលលាដ៏ក្បាលនាំឱ្យសន្លាប់ និង របួសដល់ឆ្អឹងខ្នង។
- បើមនុស្សម្នាក់នៅមានដង្ហើម និង នៅដឹងខ្លួននៅឡើយកុំឱ្យគេកំរើក លើកលែងតែត្រូវការបញ្ចេញខ្យល់ឱ្យបានស្រឡះ។
- ក្នុងករណីនេះត្រូវប្រយ័ត្នកុំឱ្យរបួសដល់ឆ្អឹងខ្នង ដោយដាក់ឱ្យគេដេកផ្អៀងយកមុខចុះក្រោម។
- ក្នុងជំហារបែបនេះ បងប្អូនត្រូវការពារកុំឱ្យឈាមដែលចេញពីមុខរបួសណាមួយក្នុងមាត់ ឬបំពង់ក រត់ចូលទៅក្នុងបំពង់សួតបាន ។
- ដាច់ខាតកុំញ៉ុកសំឡីទៅក្នុងរន្ធច្រមុះជនរងគ្រោះដើម្បីការពារ ការហូរឈាមឱ្យសោះ ។ កាលណាបើមានឈាមហូរតាមត្រចៀក សូមកុំលាងឈាមនោះចេញឱ្យសោះ ។ ប្រសិនបើជនរងគ្រោះសន្លប់ ហើយរឹងថ្គាមសូមកុំសាកល្បងគាស់បើកមាត់ឱ្យសោះ ។
- សូមកុំព្យាយាមឱ្យអ្វីទៅមនុស្សសន្លប់ផឹកឱ្យសោះព្រោះវាអាចឱ្យវត្ថុរាវនោះហូរចូលទៅក្នុងបំពង់ដកដង្ហើម និង សួតជាហេតុបណ្តាលឱ្យស្ទះខ្យល់ទៅវិញទេ ។
- នៅពេលណាមានការសង្ស័យថាជនរងគ្រោះត្រូវបាក់ឆ្អឹងខ្នង ឬ ឆ្អឹងត្រគាកគឺមានតែបុគ្គលិកដែលមានការបណ្តុះបណ្តាលទើបអាចលើកជនរងគ្រោះបាន ។

១២. របួសនៅពោះ

- បើរបួសនៅពោះបណ្តាលមកពីការប៉ះទង្គិច ឬ ក៏មានវត្ថុអ្វីមួយធ្លាក់មកលើមនុស្ស ។ល។ នោះជនរងគ្រោះត្រូវតែនាំទៅមន្ទីរពេទ្យជាបន្ទាន់ ។
- ហាមឱ្យជនដែររងរបួសហូប ឬ ផឹកទឹកអ្វីទាំងអស់។
- របួសបើកមុខត្រូវគ្របឱ្យជិតដោយប្រើក្រណាត់ស្បៃស្អាត និង សើម ។ ពេលដឹកទៅមន្ទីរពេទ្យត្រូវថែទាំជនរងគ្រោះឱ្យមែនទែន ។

១៣. ការលើកមនុស្ស



- នៅពេលជនរងរបួសត្រូវរងចាំរថយន្តពេទ្យ ត្រូវដាក់ជននោះនៅកន្លែងសុវត្ថិភាព ហើយរបៀបលើកដែលសមស្របបំផុតគឺត្រូវប្រើប្រាស់គ្រែស្នែង ឬ ភួយធំមួយ។
- ដើម្បីជួយសង្គ្រោះជនរងគ្រោះឱ្យបានឆាប់រហ័សពីកន្លែងកើតហេតុនៅក្នុងករណីគ្រោះថ្នាក់ដោយភ្លើងឆេះវិធីដ៏ល្អបំផុតគឺចាប់អូសយកជននោះចេញដោយចាប់ទាញសម្លៀកបំពាក់របស់គេ ។
- ប្រសិនបើបងប្អូននៅម្នាក់ឯង ហើយត្រូវការជំនួយមិត្តភក្តិដោយយកគេចេញយ៉ាងឆាប់រហ័សពីកន្លែងគ្រោះថ្នាក់ ។ ការលើកដូចខាងក្រោមនេះ គឺជាវិធីងាយស្រួល និង ល្អបំផុតដែលត្រូវប្រើ ។

## ✓ អគ្គិភ័យ

១. វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់ (ច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ)

- អគ្គិភ័យសំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និង បរិស្ថាន ។
- ការបង្ការអគ្គិភ័យ សំដៅដល់ការរៀបចំអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បីធានាសុវត្ថិភាព មិនឱ្យបានអគ្គិភ័យកើតឡើង ។
- ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុង និង/ឬក្រៅគោលដៅ និងវិធានការនានាដើម្បីបង្ការទប់ស្កាត់ ពន្លត់អគ្គិភ័យ និងសង្គ្រោះ ។
- មធ្យោបាយ សំដៅដល់យានយន្ត ឧបករណ៍ សម្ភារ បរិក្ខារដែលប្រើប្រាស់សម្រាប់បង្ការ និង ពន្លត់អគ្គិភ័យ ។
- ទីកន្លែងងាយឆេះ ឬ ងាយផ្ទុះឆេះ សំដៅដល់ទីកន្លែងដែលមានស្តុក ប្រើប្រាស់សារជាតុងាយឆេះ ឬ ងាយផ្ទុះឆេះ ។
- សារជាតុងាយឆេះ ឬងាយផ្ទុះឆេះ សំដៅដល់សារជាតុរាវ រឹង ឧស្ម័ន គីមី ទំនិញ ឬ វត្ថុធាតុដើមដែលងាយឆេះ ឬ ងាយផ្ទុះឆេះ ។

- ការពន្លត់អគ្គិភ័យ សំដៅដល់ការពន្លត់អគ្គិភ័យ និង ទប់ស្កាត់ការឆេះរាលដាល ដោយប្រើប្រាស់កម្លាំង ប្រើប្រាស់មធ្យោបាយពន្លត់អគ្គិភ័យ និងប្រើប្រាស់គ្រប់វិធានការផ្សេងៗទៀត។
- តំបន់ពន្លត់អគ្គិភ័យ សំដៅដល់ទីកន្លែងកំពុងឆេះ ឬប្រឈមនឹងការឆេះដែលសមត្ថកិច្ចកំពុងប្រតិបត្តិការពន្លត់អគ្គិភ័យ។
- គោលដៅ សំដៅដល់ទីកន្លែងនានា និងមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលអាចមានអគ្គិភ័យកើតឡើង។

២. មូលហេតុដែលបង្កឱ្យមានភ្លើងឆេះជាញឹកញាប់

- មនុស្សដែលធ្វើការជាមួយភ្លើង ដូចជាចុងភៅ ជាងផ្សារ ឬ អ្នកប្រកបការងារជាមួយសារធាតុដែលងាយឆេះ ការជក់បារីចោលស្រេចនឹងចិត្ត ការតខ្សែភ្លើងអគ្គិសនីមិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសធ្វើឱ្យឆ្លង ឬ ប៉ះគ្នាបង្កបណ្តាលឱ្យចេញផ្កាភ្លើង ឬខ្ទាតផ្កាភ្លើងចេញពីក្បាលរថភ្លើង ។ល។
- បញ្ហាធម្មជាតិ ដូចជាព្រៃឈើ ស្លឹកឈើ ដែលរងកំដៅខ្លាំង ហើយមានភាពស្ងួតខ្លាំង បាតុភូត រន្ទះបាញ់ ផ្ទុះភ្នំភ្លើង ។ល។

៣. បំពង់ពន្លត់អគ្គិភ័យ

**ក. Dry chemical fire extinguishers ចែកជា៣ប្រភេទ៖**

ក.១. បំពង់សុវត្ថិភាពពន្លត់អគ្គិភ័យធម្មតា Sodium bicarbonate មានប្រសិទ្ធិភាពប្រើប្រាស់តែ Class B and C ប៉ុណ្ណោះទេ វាធ្វើឱ្យខូចគុណភាពរបស់ដែលត្រូវភ្លើងឆេះនោះតិចជាងប្រភេទបំពង់ពន្លត់អគ្គិភ័យផ្សេងៗទៀត Class B ប្រេងថ្នាំលាប... Class C ខ្សែភ្លើងដែលឆ្លងប៉ះគ្នាធ្វើឱ្យភ្លើងឆេះធម្មតា ។

ក.២. Ammonium phosphate វាមានប្រសិទ្ធិភាព សំរាប់ class A,B,C ភាគច្រើន គេប្រើវាតែ Class A មួយគត់ (ឈើ ក្រដាស សំរាម ក្រណាត់...)

ក.៣. Perpurple K or Potassium Bicarbonate សម្រាប់ប្រើនៅពេលដែលភ្លើងឆាបឆេះខ្លាំងជាងធម្មតា វាធ្វើឱ្យខូចសំភារៈដែលឆេះនោះច្រើនជាងប្រភេទបំពង់ពន្លត់អគ្គិភ័យផ្សេងៗទៀត តែគេទុកវាសម្រាប់ប្រើតែ Class B and C ។

**ខ.** ១. CO2 fire extinguishers វាមានកម្លាំងបាញ់ចេញខ្លាំងជាងទឹកធម្មតាពេលបាញ់ចេញ ភ្លាមស្ងួតភ្លាម សម្រាប់ប្រើពន្លត់លើរបស់បរិក្ខារអេឡិចត្រូនិច ប្រើសម្រាប់ Class B and C ។ បំពង់ប្រភេទនេះ វាកាត់បន្ថយអុកស៊ីសែននៅកន្លែងហាប់តូចចង្អៀត គេមិនត្រូវប្រើវាទេ ។

**ខ.** ២. Class D fire extinguisher divise in 2 ៖

a. Sodium chloride កាត់បន្ថយកំដៅលោហធាតុដែលឆេះ ដូចជា Magnesium, potassium, Uranium Alumium powder

b. ម្សៅស្ពូត មានជាតិស្ពាន់ កាត់បន្ថយកំដៅនៅរបស់ដែលកំពង់ឆេះ ធ្វើឱ្យភ្លើងរលត់ភ្លាម សម្រាប់ប្រើរបស់ ដែលឆេះដូចជា Lithium ។

**គ.** Class K fire extinguisher ខ្លាញ់ ប្រេងឆា... ។

| Comparison of fire classes | | | |
|---|---|---|---|
| **American** | **European** | **Australasian** | **Fuel/Heat source** |
| Class A | Class A | Class A | Ordinary combustibles |
| Class B | Class B | Class B | Flammable liquids |
| | Class C | Class C | Flammable gases |
| Class C | Class F/D | Class E | Electrical equipment |
| Class D | Class D | Class D | Combustible metals |
| Class K | Class F | Class F | Cooking oil or fat |

Choosing Fire Extinguishers

Identify the type of materials in the area

Class A: SOLIDS such as paper, wood, plastic etc

Class B: FLAMMABLE LIQUIDS such as paraffin, petrol, oil etc

Class C: FLAMMABLE GASES such as propane, butane, methane etc

Class D: METALS such as aluminium, magnesium, titanium etc

Class E: Fire involving ELECTRICAL APPARATUS

Class F: Cooking OIL & FAT etc

៤. វិធានការណ៍ការពារនឹងទប់ទល់ពេលមានបំពង់ពន្លត់អគ្គិភ័យ

ក. វិធានការណ៍ការពារ

- រោងចក្រត្រូវធ្វើការសាកល្បងដល់កម្មករទាំងអស់យ៉ាងហោចណាស់ក៏១ឆ្នាំឱ្យបាន១ដងដែរនូវវិធានការណ៍ចាកចេញពីរោងចក្រជាបន្ទាន់នៅពេលឮកណ្តឹងប្រកាសអាសន្ន ។
- ត្រូវបង្រៀនកម្មករនិយោជិតទាំងអស់ឱ្យចេះពីរបៀបប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យ នៅពេលមានភ្លើងឆេះធម្មតា ពួកគេអាចជួយបាន ។
- អ្នកគ្រប់គ្រង ឬ អ្នកទទួលខុសត្រូវទាំងអស់ត្រូវចេះរបៀបប្រើបំពង់ពន្លត់អគ្គិភ័យ នឹងជាអ្នកនាំកម្មករចាកចេញពីរោងចក្រនៅពេលមានភ្លើងឆេះ។
- ត្រូវបង្រៀនអ្នកធ្វើការទាំងអស់ឱ្យយល់ពីមូលហេតុ នឹងស្គាល់ពីសារធាតុដែលងាយឆេះ។

ខ. ចំណុចដែលត្រូវត្រួតពិនិត្យ

- តើនៅកន្លែងធ្វើការមានបិទ នឹងធ្វើការផ្សព្វផ្សាយស្តីពីនីតិវិធី ដែលត្រូវអនុវត្តជាចាំបាច់នៅពេលមានអគ្គិភ័យកើតឡើងឬទេ ?

- តើកម្មករនិយោជិតទាំងអស់យល់ដឹង នឹងចេះអនុវត្តតាមនីតិវិធីដែលបានបង្ហាត់បង្រៀនឬទេ ?
- តើរោងចក្រមានបានធ្វើការសាកល្បងតាមកាលកំណត់ដែលឬទេ ?
- តើទ្វារសម្រាប់ចាកចេញមានគ្រប់គ្រាន់នឹងមានភាពងាយស្រួលដែរទេ ?
- តើទ្វារសម្រាប់ចាកចេញមានដាក់សញ្ញា ឬ ភ្លើងសំគាល់ឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យដែលដាក់តាមផ្នែក មានដាក់តាមក្រុមសម្រាប់ពន្លត់របស់ដែលត្រូវឆេះឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យមានគ្រប់គ្រាន់ឬទេ ?
- តើមានសញ្ញាបង្ហាញពីកន្លែងដាក់បំពង់ពន្លត់អគ្គិភ័យឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យដែលដាក់ជាប់ជញ្ជាំង មានផ្លូវស្រឡះនឹងងាយស្រួលយកមកប្រើប្រាស់ឬទេ ?
- តើមានបានសាកល្បង បញ្ជាក់ថាបំពង់ពន្លត់អគ្គិភ័យទាំងអស់សុទ្ធតែប្រើបានឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យ បានត្រួតពិនិត្យនឹងថែរក្សាជាប្រចាំបានល្អឬទេ ?
- តើមានផែនទីបង្ហាញពីកន្លែងទុកបំពង់ពន្លត់អគ្គិភ័យឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យត្រូវមានពណ៌បញ្ជាក់ពីប្រភេទនៃបំពង់ពន្លត់អគ្គិភ័យដែលឬទេ ?
- ត្រួតពិនិត្យមើលសារជាតុដែលងាយឆេះ ត្រូវដាក់ឱ្យដាច់ពីគ្នា នឹងឱ្យឆ្ងាយពីរបស់ផ្សេងៗទៀត។
- ត្រូវកាត់បន្ថយនាំចូលសារជាតុដែលងាយឆេះ ក្នុងម៉ោងធ្វើការ ។
- ត្រូវចេះសំអាតកន្លែងធ្វើការឱ្យបានស្អាតជានិច្ច ជាពិសេសកន្លែងដែលបង្កឱ្យឆេះ ព្រោះកន្លងមកបញ្ហាដែលបណ្តាលឱ្យឆេះតែងមានកើតឡើងជាដដែលៗ។
- តើមានផែនការចាកចេញពីរោងចក្រ ទៅតាមជាន់របស់វាដែលឬទេ ?

៥. នីតិវិធីដែលត្រូវអនុវត្ត ជាបន្ទាន់នៅពេលមានអគ្គិភ័យកើតឡើង

- ពេលមានភ្លើងឆេះកើតឡើង តើយើងត្រូវធ្វើដូចម្តេច ?
- កុំឱ្យភ័យស្លន់ស្លោរ ឬរត់ឆ្លេរឆ្លា ឬស្រែកផ្អើលឆោឡោឱ្យសោះ។
- ភ្លាមៗ ត្រូវចុចកណ្ដឹងប្រកាសអាសន្នដែលនៅជិត (ប្រអប់ពណ៌ក្រហម)។
- ទូរស័ព្ទទៅភ្នាក់ងារពន្លត់អគ្គិភ័យ ប្រាប់ឈ្មោះ ទីកន្លែងឱ្យបានច្បាស់លាស់ បើអាចប្រាប់បានត្រូវប្រាប់ពីមូលហេតុ នៃភ្លើងឆេះ តើឆេះរបស់អ្វីខ្លះ ឆេះមានទំហំតូច ឬធំ តើរាលដាលលឿនឬទេ ?
- បើមានភ្លើងឆេះ ទំហំ ឬ ទ្រង់ទ្រាយតូច បើអាចពន្លត់បានត្រូវពន្លត់ភ្លាមដោយមិនបាច់ទូរស័ព្ទ ហើយបើប្រើអស់ ១បំពង់មិនរលត់ ត្រូវទូរស័ព្ទភ្លាម។

- ត្រូវរត់ចេញពីអគារភ្លាមតាមសញ្ញាសុវត្ថិភាព នឹងតាមទ្វារដែលនៅក្បែរ បើអាចធ្វើបានត្រូវទ្វារបន្ទាប់ដែលឆេះ មុនរត់ចេញ។

៦. សកម្មភាពពេលឮកណ្តឹងប្រកាសអាសន្ន

- កុំឱ្យភ័យស្លន់ស្លោរ ឬ រត់ឆ្វេរឆ្វា នាំឱ្យផ្អើលដល់គេទាំងអស់គ្នា។
- ដើរចេញភ្លាម តាមទ្វារដែលនៅក្បែរ ដោយយករបស់សំខាន់ជាប់មកជាមួយ ត្រូវដើរតាមសញ្ញាសុវត្ថិភាព មិនត្រូវរត់ឆ្វេរឆ្វាឡើយ ។ បើនៅជាន់លើត្រូវចុះតាមកាំជណ្តើរហាមចុះតាមជណ្តើរយន្តត្រូវបិទទ្វារបន្ទប់ ដែលឆេះមុនចាកចេញបើអាចធ្វើទៅបាន ។
- ត្រូវធ្វើតាមបញ្ជាភ្នាក់ងារពន្លត់អគ្គិភ័យ។
- កាលណាឮកណ្តឹងត្រូវដឹងថាជាកណ្តឹង ប្រកាសអាសន្នមែនទែន រួចត្រូវធ្វើតាមនីតិវិធីដែលគេធ្លាប់បានសាកល្បង កន្លងមកដោយចាកចេញភ្លាមៗហាមចុះតាមជណ្តើរយន្ត ។
- ត្រូវដើរតៗគ្នា មិនត្រូវរត់ ឬប្រជែងគ្នាចេញឡើយ គឺត្រូវដើរចេញតាមលំដាប់លំដោយចំពោះអ្នកដែលចេញក្រោយគេ បើអាចធ្វើបានត្រូវបិតទ្វារបន្ទប់ឆេះមុនចាកចេញ។
- កំពុងតែដើរ បើមានដុំភ្លើងឆេះ ធ្លាក់ពីលើចំពីមុខ ត្រូវដើរវាងទៅផ្លូវផ្សេងភ្លាម ។
- ពេលចេញផុតពីអគារ ត្រូវដើរទៅឱ្យឆ្ងាយពីអគារ ទុកកន្លែងឱ្យអ្នកដែលដើរមកពីក្រោយយើង។
- បើអាចសង្គ្រោះបាន សូមជួយសង្គ្រោះជនពិការ ឬ អ្នកដែលត្រូវរបួសផង។
- កុំចូលទៅក្នុងអគារវិញដាច់ខាត ទោះជាមានការបាច់យ៉ាងណាក៏ដោយរហូតដល់មានបញ្ជាពីអ្នកពន្លត់អគ្គិភ័យ ទើបអាចចូលបាន ។
- ពេលលែងឮកណ្តឹងរោទិ៍ប្រកាសអាសន្ន កុំដើរចូលមកក្នុងអគារវិញឱ្យសោះ ។

- ផ្ទាំងរបបអាហារទាំងបីក្រុម

★ រូបភាពផ្ទាំងរបបអាហារទាំងបីក្រុម









- ពាក្យស្លោកអប់រំ

★ ផ្ទាំងពាក្យស្លោកអប់រំ




































- ខិត្តប័ណ្ណ

★ រូបភាពខិត្តប័ណ្ណអប់រំ



- ស្តួតអប់រំស្តីពី៖
  - អត្ថប្រយោជន៍របបសន្តិសុខសង្គម
  - របបអាហារទាំងបីក្រុម
  - ការងារថែមម៉ោង
  - ការបង្ការគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត
  - ណែនាំពីបច្ចេកទេសថែទាំយានយន្ត
  - សារសំខាន់នៃបណ្ណបើកបរ
  - សង្គ្រោះបឋម

✓ **អំពីកិច្ចប្រជុំផ្សព្វផ្សាយអប់រំក្នុងឆ្នាំ២០១៦**

អនុលោមតាមលទ្ធផលសន្និបាតបូកសរុបការងារឆ្នាំ២០១៥ និងទិសដៅឆ្នាំ២០១៦ នៃការអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ២០១៤-២០១៨ ត្រង់ចំណុចទី១៣ នៃទិសដៅអនុវត្តបន្តឆ្នាំ២០១៦ឱ្យបាន២០០% នៃឆ្នាំ២០១៥។ ជាមួយនឹងការយកចិត្តទុកដាក់ពី លោកនាយក ប.ស.ស ក្នុងការបង្កើនអនុវត្តការផ្សព្វផ្សាយការបង្ការទប់ស្កាត់គ្រោះថ្នាក់ការងារ និងការជួលសន្លប់ក្នុងឆ្នាំ២០១៦នេះ ក្រុមការងារបានចុះទំនាក់ទំនងជាមួយនឹងនិយោជករោងចក្រ ដើម្បីរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំដូចភ្លៀងរលឹម ដើម្បីឱ្យនិយោជក ឬ តំណាងសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទទួលបាននូវចំណេះដឹង ស្តីពីលក្ខខណ្ឌការងារ,លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ (ការទប់ស្កាត់កម្មករនិយោជិតសន្លប់), អត្ថប្រយោជន៍នៃការអនុវត្តរបបសន្តិសុខសង្គម និងបង្ការគ្រោះថ្នាក់ការងារ ពិសេសការចូលរួមកាត់បន្ថយកម្មករនិយោជិតសន្លប់ឱ្យស្ថិតនៅកំរិតក្បែរនឹងលេខសូន្យ។

ទោះបីចំនួនរោងចក្រកាត់ដេរ និង ផលិតស្បែកជើងចំនួន **១,០០៦** រោងចក្រ និងកម្មករនិយោជិតចំនួន **៦៨៧,៦៨៦**នាក់ ក្នុងនោះមានរោងចក្រសន្លប់ ក្នុងឆ្នាំ២០១៦នេះ មានចំនួន **១៨** រោងចក្រ ស្មើនឹង **១.៧%** និងកម្មករនិយោជិតសន្លប់ **១,១៦០** នាក់ ស្មើនឹង **០.១៦%** ។ តាមការវិភាគរកឃើញថា បញ្ហាគីមី, បញ្ហារូបសាស្រ្ត, បញ្ហាជីវសាស្រ្ត, បញ្ហាចិត្តសាស្រ្ត, បញ្ហាមេកានិច, បញ្ហាវិទ្យាសាស្រ្តរៀបចំការងារ និងបញ្ហាថែមម៉ោង ក្នុងចំណោមបញ្ហាទាំងប្រាំពីរ គឺជាដើមហេតុដែលបណ្តាលឱ្យកម្មករនិយោជិតសន្លប់ ពិសេស បញ្ហាចិត្តសាស្រ្តសង្គម ដែលមានភាគរយច្រើន។

ការផ្សព្វផ្សាយអប់រំក្នុងឆ្នាំ២០១៦ នេះ ក្រុមការងារ ទ.ស.ប.ក បានរៀបចំបាន ចំនួន ៧៧ លើក ស្មើនឹង ៧៧ រោងចក្រ និងកម្មករនិយោជិតចូលរួមប្រមាណជា ១៣,០៤២ នាក់ (និយោជក/តំណាងនិយោជក/រដ្ឋបាល, តំណាងសហជីពមូលដ្ឋាន, ប្រតិភូបុគ្គលិក, ប្រធានក្រុម/ផ្នែក, កម្មករនិយោជិត និងគ្រូពេទ្យគិលានដ្ឋាន និងសន្តិសុខរោងចក្រ)។ ទន្ទឹមនឹងការងារនេះ ប.ស.ស ក៏បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញទប់ស្កាត់ករណីសន្លប់ និងជួយសង្គ្រោះកម្មករសន្លប់ តាមសហគ្រាស គ្រឹះស្ថាន ដែលសម្រេចបានដូចខាងក្រោម៖

- ការផ្សព្វផ្សាយអប់រំអំពី លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ, លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម

| ល.រ | បរិយាយ | ឆ្នាំ២០១៦ | | | ឆ្នាំ២០១៥ | | | កំណើន % | | |
|---|---|---|---|---|---|---|---|---|---|---|
| | | រោងចក្រ | កម្មករ | ស្រី | រោងចក្រ | កម្មករ | ស្រី | រោងចក្រ | កម្មករ | ស្រី |
| | សរុបរួម | 77 | 13,042 | 11,738 | 90 | 13,450 | 12,105 | -14.44% | -3.03% | -3.03% |
| ១ | រាជធានីភ្នំពេញ | 70 | 12,079 | 10,871 | - | . | - | - | - | - |
| ២ | ខេត្តតាកែវ | 1 | 135 | 122 | - | - | - | - | - | - |
| ៣ | ខេត្តកំពង់ស្ពឺ | 6 | 828 | 745 | - | - | - | - | - | - |

- វគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ

| បរិយាយ | វគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ | | | |
|---|---|---|---|---|
| | លើក | អ្នកចូលរួម | | ផ្តល់វិញ្ញាបនបត្រ |
| | | សរុប | ស្រី | |
| ឆ្នាំ២០១៦ | 5 | 429 | 260 | 429 |
| ឆ្នាំ២០១៥ | 0 | 0 | 0 | 0 |
| កំណើនភាគរយ | - | - | - | - |

## ខ. បញ្ហាប្រឈម

### ❖ កត្តាកម្មករនិយោជិត

- ធ្វើការថែមម៉ោងច្រើនលើសពីការអនុញ្ញាតរបស់ក្រសួង បានធ្វើឱ្យសុខភាពចុះខ្សោយ
- បរិភោគអាហារមិនមានជីវជាតិ កង្វះអនាម័យ ហើយជួនកាលខកខានបរិភោគអាហារទៀត
- សម្រាកមិនបានគ្រប់គ្រាន់
- មានស្ថានភាពតានតឹងក្នុងអារម្មណ៍

### ❖ កត្តានិយោជក

- រោងចក្រមួយចំនួនមិនព្រមចូលរួមសហការរាយការណ៍ចំនួនកម្មករនិយោជិតពិតប្រាកដមកឱ្យ ប.ស.ស នោះឡើយ
- រោងចក្រមួយចំនួនឱ្យកម្មករនិយោជិតថែមម៉ោងលើសពីការអនុញ្ញាតរបស់ក្រសួង
- រោងចក្រមួយចំនួនមានបរិយាការណ៍កំដៅ ក្តៅ និងហប់
- ការធ្វេសប្រហែសត្រួតពិនិត្យផ្នែកសុខភាព និងសុវត្ថិភាពការងារជាប្រចាំរបស់និយោជក
- និយោជកបានកែលំអវិធានការរបស់ក្រុមការងារ ទ.ស.ប.ក មានសភាពយឺតយ៉ាវ

### ❖ កត្តាក្រសួង

- រៀបចំផ្សព្វផ្សាយអប់រំ និងត្រួតពិនិត្យលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារតាមបណ្តារោងចក្រកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង នៅពុំទាន់បានឆ្លើយតបទៅនឹងបរិមាណនៃចំនួនរោងចក្រដែលដំណើរការបច្ចុប្បន្ន
- ផ្សព្វផ្សាយការអនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅតាមបណ្តាសហគ្រាស គ្រឹះស្ថានមិនទាន់បានទូលំទូលាយនៅឡើយ ។

## គ. ដំណោះស្រាយ

### ❖ ចំពោះមុខ

- បញ្ជាឱ្យរោងចក្រដែលមានគ្រោះថ្នាក់ ផ្អាកការងារជាបណ្តោះអាសន្ន
- ចាត់មន្ត្រីជំនាញជួយសង្គ្រោះ និង តាមដានឃ្លាំមើលសភាពកម្មករនិយោជិតនៅនឹងកន្លែងគ្រោះថ្នាក់ទាន់ពេលវេលានិងជាប់ជាប្រចាំរហូតដល់កន្លែងធ្វើការវិលមកស្ថានភាពប្រក្រតីវិញ
- ទទួលរ៉ាប់រងព្យាបាលដោយឥតគិតថ្លៃដល់ជនរងគ្រោះទាំងអស់ តាមរយៈ ប.ស.ស
- ចាត់វិធានការកែតម្រូវលក្ខខណ្ឌបច្ចេកទេសនានាដែលបានពិនិត្យឃើញថាមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ចាត់មន្ត្រីតាមដានពិនិត្យអំពីស្ថានភាពរោងចក្រមុននឹងអនុញ្ញាតឱ្យដំណើរការឡើងវិញ

❖ **ជាយុទ្ធសាស្ត្រ**

- ក្រសួងបានបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និង បង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត (ទ.ស.ប.ក) ដែលក្រុមការងារនេះ មានភារកិច្ចចំបងក្នុងការសិក្សាស្រាវជ្រាវកំណត់ឱ្យបានច្បាស់លាស់នូវមូលហេតុដែលនាំឱ្យមានបាតុភាពសន្លប់ជារួមនៅកន្លែងធ្វើការ និងកំណត់វិធានការបង្ការបានត្រឹមត្រូវ សំដៅធានាការពារសុខមាលភាពកម្មករនិយោជិត
- ក្រសួងបានពង្រឹងបន្ថែមការអនុវត្តច្បាប់ និង បទប្បញ្ញត្តិជាធរមាន ជាពិសេសចំពោះបណ្តារោងចក្រសហគ្រាសកាត់ដេរ និង ស្បែកជើងដែលមានកម្មករនិយោជិតច្រើនជាងវិស័យដទៃផ្សេងទៀត
- រៀបចំយុទ្ធនាការផ្សព្វផ្សាយអប់រំដល់និយោជក និង កម្មករនិយោជិតឱ្យយល់ដឹងពីលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យសុវត្ថិភាពការងារ ការថែទាំសុខភាព ការការពារបរិស្ថាននៅកន្លែងធ្វើការជាដើម
- ក្រសួងស្នើឱ្យរោងចក្របង្កើតឱ្យមានគណៈកម្មការសុខភាព សុវត្ថិភាពការងារនៅនឹងកន្លែងការងារ

## ឃ. ការងារអនុវត្តបន្ត

- រៀបចំប្រជុំផ្ទៃក្នុងក្រុមការងារ ទ.ស.ប.ក
- រៀបចំចុះតាមរោងចក្រ សហគ្រាសគ្រឹះស្ថាន ដែលមានករណីកម្មករនិយោជិតសន្លប់
- សិក្សាស្រាវជ្រាវមូលហេតុដែលបណ្តាលឱ្យកម្មករនិយោជិតសន្លប់
- រៀបចំផ្សព្វផ្សាយអប់រំតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន
- រៀបចំឯកសារពាក់ព័ន្ធសម្រាប់ផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ចផ្សេងៗតាមការប្រគល់ជូនរបស់ថ្នាក់ដឹកនាំ។

## ខ. សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ២០១៦ ក្រុមការងារ ទ.ស.ប.ក ត្រូវបានអនុវត្តការងារយ៉ាងសស្រាកសស្រាំក្នុងទិសដៅបម្រើកម្មករនិយោជិត ដោយឆន្ទៈទទួលខុសត្រូវខ្ពស់ តាមរយៈការចុះទៅសម្របសម្រួលពិនិត្យ អង្កេតស្វែងរកមូលហេតុដ៏ជាក់លាក់ ដើម្បីចាត់វិធានការឱ្យនិយោជករោងចក្រ សហគ្រាស គ្រឹះស្ថាន រៀបចំធ្វើការកែលំអបានចំគោលដៅ និងទាន់ពេលវេលា។

ទន្ទឹមនឹងនោះ ក្រុមការងារ ទ.ស.ប.ក ក៏បាននិងកំពុងរៀបចំយុទ្ធនាការផ្សព្វផ្សាយអប់រំនៅនឹងកន្លែងការងារនៅតាមបណ្តារាជធានី-ខេត្ត ស្តីពីលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ (ការទប់ស្កាត់ករណីកម្មករនិយោជិតសន្លប់) និងអត្ថប្រយោជន៍នៃការអនុវត្តរបបសន្តិសុខសង្គម ក្នុងន័យការពារ និងបង្ការហានិភ័យការងារ (គ្រោះថ្នាក់ការងារ)។ នៅក្នុងកិច្ចប្រជុំនេះដែរ ក្រុមការងារ ទ.ស.ប.ក បានធ្វើបទបង្ហាញលំអិត និង ចែកជូនកម្មករនិយោជិតនូវឯកសារមេរៀន ខិត្តបណ្ណ ទឹកសុទ្ធ នំប៉ុង(នំផ្អែម) និង ប្រាក់ឧបត្ថម្ភ លើសពីនោះ ក្រុមការងារបានបិទបង្ហាញបដាពាក្យស្លោក, ផ្ទាំងរូបភាពរបបអាហារ និងលេខទូរស័ព្ទបន្ទាន់ ១២៨៦ ផងដែរ។

ក្នុងន័យខាងលើ ក្រុមការងារ ទ.ស.ប.ក និងប.ស.ស សង្ឃឹមយ៉ាងមុតមាំថា ការផ្សព្វផ្សាយអប់រំនេះ នឹងមានការចូលរួមអនុវត្តរបស់កម្មករនិយោជិត និងនិយោជកបានយ៉ាងខ្ជាប់ខ្ជួនជាក់ជាពុំខាន ដែលជាប្រយោជន៍យ៉ាងធំធេង និង ប្រពៃថ្លៃថ្លា ក្នុងការធានាបាននូវ "**សុខដុមរមនានៅកន្លែងការងារកាន់តែប្រសើរឡើង ពិសេសករណីកម្មករនិយោជិតសន្លប់នឹងត្រូវបានកាត់បន្ថយក្នុងកម្រិតខ្ពស់**"៕

## ★ ឯកសារយោង

- ច្បាប់ស្តីពីការងារ
- ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- សេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារទប់ស្កាត់ករណីសន្លប់ និង បង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត (ទ.ស.ប.ក)
- សេចក្តីសម្រេច ស្តីពីការបន្ថែមសមាសភាពក្រុមការងារទប់ស្កាត់ករណីសន្លប់និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត (ទ.ស.ប.ក)
- ផែនការសកម្មភាពផ្សព្វផ្សាយ អប់រំ និងបង្ការឆ្នាំ២០១៦
- របាយការណ៍បូកសរុបរបស់ក្រុមការងារ ទ.ស.ប.ក ក្នុងឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត
- កំណត់ហេតុចុះរោងចក្ររបស់ក្រុមការងារ ទ.ស.ប.ក ក្នុងឆ្នាំ២០១៥ និងកំណត់ហេតុក្រុមការងារ ទ.ស.ប.ក ក្នុងឆ្នាំ២០១៦

## ★ ទំនាក់ទំនងផ្ទាល់

### ១. ប.ស.ស

| | |
|---|---|
| - លេខទូរស័ព្ទ៖ | ០២៣ ៨៨២ ៤៣៤ / ០២៣ ៩៩៨ ៤១៨<br>០២៣ ៩៩៨ ៤១៧ / ០២៣ ៩៩៨ ៤១៩ |
| - លេខទូរសារ៖ | ០២៣ ៨៨២ ៦២៣ |
| - គេហទំព័រ (Website)៖ | www.nssf.gov.kh |
| - Page Facebook ប.ស.ស | facebook.com/nssfpage |
| - សារអេឡិចត្រូនិច (E-mail)៖ | info@nssf.gov.kh |
| - **លេខទូរស័ព្ទទំនាក់ទំនងបន្ទាន់** | (Hotline) **១២៨៦** |

### ២.លេខទូរស័ព្ទក្រុមការងារ និងលេខាធិការដ្ឋាន (ទ.ស.ប.ក)

- **ក្រុមការងារ ទ.ស.ប.ក**

  ០១២ ៨៩៨ ៧៨៥ / ០១២ ៩៨៣ ៧១០ / ០១២ ២២៤ ២២២

  ០១២ ៥៧៩ ៤១១ / ០១២ ៩៨៨ ៤១៨ / ០១២ ៥០២ ១៤៩

- **លេខា ទ.ស.ប.ក**

  ០១២ ៧៩០ ៧១២ / ០១២ ៩០៣ ៩២៨

  ០៧០ ៨៨១ ២២២ / ០១០ ៣៧០ ៣៣០

# សកម្មភាពរបស់ក្រុមការងារ ទ.ស.ប.ក
# ឆ្នាំ២០១៦



ពិធីផ្សព្វផ្សាយអប់រំអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ
លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម



ពិធីផ្សព្វផ្សាយអប់រំអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ
លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម



ពិធីផ្សព្វផ្សាយអប់រំអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ
លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម



ករណីសន្លប់របស់កម្មករនិយោជិតនៅក្នុងរោងចក្រ ជៀន ស៊ិន(ខេមបូឌា)
ខូអិលធីឌី (រាជធានីភ្នំពេញ)



សកម្មភាពកម្មករនិយោជិតចូលរួមប្រជុំស្តីពី លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ
លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម


លេខទូរស័ព្ទ: ០២៣ ៨៨២ ៤៣៤ / ០២៣ ៩៩៨ ៤១៧
០២៣ ៨៨២ ៤៣៤ / ០២៣ ៩៩៨ ៤១៧

លេខទូរស័ព្ទបន្ទាន់ (គ្រោះថ្នាក់ការងារ)

**Hotline: 1286**

អាសយដ្ឋាន: អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ